# ឧទ្ទិស

ប្រលោមលោកនេះ បានក្រងកើតឡើងក្នុងសម័យដែលប្រទេសកម្ពុជាត្រូវបែង
អាណាខេត្តខាងលិច ទៅនៅក្រោមអំណាចប្រទេសជិតខាង គឺរវាង ៧ ឆ្នាំមកហើយ ។

ដូច្នេះហើយសេចក្ដីរលឹកដល់ភូមិកំណើត ដល់ញាតិមិត្តដែលព្រាត់ទៅម្ខាងៗ
ព្រំដែនអកុសល ក៏សឹងមានងំនៅក្នុងថ្លើម ក្នុងប្រមាត់នៃខ្មែរគ្រប់ៗរូប ។

ដូច្នេះហើយបានជាកន្លែងណា តំបន់ណាដែលជាទីស្រឡាញ់របស់អ្នកតែង
ក៏ត្រូវកំឡាំងនៃសេចក្ដីរលឹក ច្រានបញ្ជូនមកជាក្របខ័ណ្ឌនៃរឿងនេះ ។

ដូច្នេះហើយបានជាខ្ញុំឧទ្ទិសរឿងនេះ ជូនចំពោះដែនកំណើតរបស់ខ្ញុំ ។

ភ្នំពេញ, ១៥ កក្កដា ២៤៩០

# ជំរាបអ្នកអាន

សៀវភៅ ដែលលោក - អ្នកចាប់ផ្ដាត់ទំព័រមើលក្នុងពេលនេះ បាននិពន្ធរួចជាយូរឆ្នាំហើយ តែពុំមានឱកាសនឹងបោះពុម្ពនោះ ។ កាលពីថ្ងៃ១៩ កក្កដា គ.ស ១៩៤៧ កាសែត កម្ពុជា បានចុះផ្សាយបន្តិចម្ដងៗ រាល់ថ្ងៃសៅរ៍ ដរាបដល់ថ្ងៃ២៧ កញ្ញា ឆ្នាំដដែលទើបចប់ តែដោយឃើញថា ជាការរាត់រាយពេក ទើបមានមិត្តជាច្រើននាក់សុំឲ្យប្រមូលបោះជាសៀវភៅឡើង ។

ឥឡូវ សេចក្ដីបំណងនេះបានសំរេចហើយ តែអ្នកនិពន្ធសូមអភ័យទោសចំពោះលោក - អ្នកប្រាជ្ញទាំងឡាយបើឃើញថាមានឆ្គាំឆ្គង ព្រោះជាជំហានដើមបំផុតក្នុងអក្សរសាស្ត្រជាតិ ។

ន ហ

# ១

រទេះភ្លើងបោលលឿនដូចព្យុះកាត់ព្រៃខ្លុង និងព្រិចរត់ឆ្លងអូរ ហើយជ្រែកពុះជើងភ្នំ ដោយបញ្ចេញសន្ធឹកខ័ររំពងធ្វើឲ្យរញ្ជួយផែនពសុធា ។

បន្តិចក្រោយមកយាននោះក៏បើកផុតជួរភ្នំ និងព្រៃស្ងាត់អស់ ហើយបើប្រសិនជាគេអើតតាមបង្អួចនៃទូណាមួយទៅ គេនឹងឃើញវាលស្រែដ៏មានភ្លឺខ្មៅប្រជេះ ខ្វែងកាត់ជាក្រឡាចត្រង្គប្រកបដោយកិរិយាចេះរត់ថយក្រោយវិញ ។

វាលស្រែ ! វាលស្រែ ! ពាសពេញតៗ ជាប់គ្នាដល់ជើងព្រៃដែលគេមើលទៅឃើញខៀវសន្លឹម ។

នៅក្នុងស្រែ សុទ្ធតែមានទឹកសស្វាច ពេញព្រៀបដែលខ្យល់រំហើយបោកបក់បណ្ដាលឲ្យកើតជារលកពព្រាំមកយោលដើមស្រូវខ្ចី ពណ៌បៃតងស្រស់ ។

នៅក្នុងជំពូកគុម្ពស្រូវនោះ មានផ្កាត្រកួនពណ៌ស្វាយ ផ្កាក្រជីបពណ៌ក្រហមឆ្អៅ ផ្កាអញ្ចាញពណ៌លឿងដូចមាសឆ្អិន លាយឡំគ្នាត្រង់នេះបន្តិច ត្រង់នោះបន្តិច ។ បុប្ផាទាំងនេះ ហាក់ដូចជាឧប្បត្តិកឡើង សំរាប់ជាគ្រឿងលំអនៃសំពត់ព្រំពណ៌បៃតង ដែលលាតសន្ធឹងក្រោមមេឃស្រកានាគ និងក្រោមរស្មីថ្លាត្រចះនៃព្រះសុរិយា ។

នៅក្នុងទឹកថ្លាខ្យង កុកចុះរកស៊ីសព្រាតទាំងហ្វូងៗ និងមានគ្រួសារ ឬចង្កៀលខ្យង ដើរគូៗវា ។ ឆ្ងាយពីទីនេះបន្តិចទៅហ្វូងប្រវឹកហែលប្រដេញគ្នាតាមគុម្ពរល្វើវារីជាតិ ។ ឯពួកអ្នកស្ទូងដែលស្លៀកពាក់ខ្មៅ ហើយប្រឡាក់ភក់ស្រមកបាននាំគ្នាងើបមើលខ្សែរទេះភ្លើង ធ្វើភ្នែកស្លឹង ។

ពួកសិស្សវិទ្យាល័យដែលត្រូវបានឈប់សំរាកពីរខែ បានស្រុះគ្នាធ្វើដំណើរត្រឡប់ចូលទៅក្រុងបាត់ដំបងវិញ ដោយអឺកធឹក : ខ្លះផ្ដិតែន ខ្លះទះដៃ ខ្លះទន្ទ្រាំក្ដារបន្ទរ ហើយខ្លះច្រៀងទំនុកបារាំង ដែលគេធ្លាប់ឮ អ្នកលេងកុនឈ្មោះទីណូរូសស៊ីច្រៀង ។ ក្មេងមួយនាក់ឈ្មោះបូណា ចេះប្រសប់យ៉ាងចំឡែកខាងធ្វើគ្រាប់សំដី និង



កិរិយានៃគ្រូអាចារ្យ ដែលជាហេតុបណ្ដាលអោយសំណើចផ្ទុះឡើងឮទ្រហឹងអឹងអាប់ ។ យុវជនខ្លះទៀតដែលមានឫកពាជាអ្នកសុភាពរម្យទម ឈរនៅមាត់បង្អួចមើលសត្វហើរមនុស្សធ្វើការ និងទេសភាពនានា ហើយមានទឹកមុខរីកថ្លាហាក់ដូចជាបានជួបនឹងមិត្តភ័ក្តិ ។

វ៉ាកងធំ ! អ្នកអានទាំងឡាយគង់ជ្រាបស្រាប់ហើយ នូវកំលាំងនៃសេចក្ដីសប្បាយដែលពង្រីកទ្រូង នៃយុវជនលាសារៀន នៅពេលដែលចំពើបលើ ឈប់ពីរខែ វ៉ាកងធំ ! ឈប់ពីរខែ ! ពាក្យចំឡែកអស្ចារ្យដែលបើកទ្វារជើងមេឃធំ ទូលាយទៅខាងមុខបាន ។ បក្សាដែលគេបង្ខាំងនៅក្នុងទ្រុង ហើយបើគេបើកទ្វារលែងទៅ មានសេចក្ដីត្រេកអរ យ៉ាងណាមិញក្មេងសិស្សទាំងឡាយក៏សប្បាយយ៉ាងនោះដែរ ។ ខ្លួនគេដូចជាស្រាលចង់រសាត់អណ្ដែតទៅតាមអាកាស កិរិយាគេដូចជាមនុស្សស្រវឹង គឺ ស្រវឹងនឹងសេរីភាព ! ឈប់ពីរខែ ! គេមិនដែលឃើញសប្បាយអ្វីបានយូរដល់ម្ល៉េះទេ ។ គេរួចពីចំណងការរៀនសូត្រ ដែលត្រូវបំពេញរាល់ថ្ងៃជាអចិន្ត្រៃយ៍ ។ លាហើយសៀវភៅធំៗដ៏មានវិជ្ជាពិបាក ឡើងងងឹតមុខ ! លាហើយសំឡេងគ្រូអាចារ្យដែលបង្ខិតបង្ខំស្ដីបន្ទោស លាហើយគ្រែដំណេកដែលមានសង្កើចពាសពេញ ! លាហើយកន្លែងទទួលភោជនាហារដែលធំក្លិនឆ្អាបៗជាប់នឹងច្រមុះ ! លាហើយពួកម៉ាកដែលធ្លាប់ស្រឡាញ់គ្នា ដែលខំប្រកួតប្រណាំងគ្នា ... លាហើយ ! លាហើយ ! លាហើយ!គេនឹងទៅជួបជុំ ឪពុកម្ដាយ បងប្អូនញាតិសន្ដាន ។ គេនឹងបានដេកអស់ពេលតាមចំណង់ បរិភោគតាមឃ្លាន ដើរលេងតាមកំសាន្ត ។ ឈប់ពីរខែ ជយោ !

ក្នុងចំនោមជនដែលកំពុងត្រេកត្រអាលយ៉ាងនេះ ! អ្នកទាំងឡាយគ្មាននឹកនាថានឹងមាននរណាធ្វើមុខជូរ កើតទុកបានឡើយ ។ តែបើសំឡឹងគយគន់ឲ្យហ្មត់ចត់ទៅក៏នឹងឃើញកុមារម្នាក់ដែលមានរូបរាងដូចជា ចៅចិន មានអាយុប្រហែល ១៨ឆ្នាំ មុខរាហ៍សម្បុរជ្រះ រាងមាំដោយប្រព្រឹត្តកីឡា ហើយមានកំពស់យ៉ាងបង្គួរ ។ យុវជននោះអង្គុយសញ្ចប់ ទឹកមុខស្ងប់ស្រពោននៅក្នុងយានតែម្នាក់ឯង ។ ឯសក់សំពោង ដែលអណ្ដែត

សំផុរទៅដោយល្បឿនខ្យល់ និងខោអាវសៗ កាត់តាមនិយមអឺរ៉ុប ដែលមានប្រលាក់ពាសពេញ សំដែងឲ្យ ឃើញថាអ្នកកំលោះមានទុក្ខជាទម្ងន់ ។

ស្ថានីយ៍អូស្រឡៅ ! ក្មេងនោះក្រោកឈរឡើង ហើយអើតតាមបង្អួចមើលទៅខាងកើត ។ ក្នុងគ្រានេះ អារម្មណ៍ផ្សេងៗក៏ស្ទុះមកបោសអង្អែលព្រលឹងនាយកំលោះមានសភាពដូចជាវាយោរហៀកៗដែលតែងរំហើយរាត្រីនៃរដូវក្ដៅ ។ ឱវាលស្រែនេះ ! ជួរជងអូរនេះ ! ឱ ! ត្រដោកហ្វូងគោក្របីដែលស៊ីស្មៅព្រាតនោះ ! ខ្លួនបានធ្លាប់ស្គាល់ធ្លាប់ប្រទះ តែទោះឃើញយ៉ាងណាក៏ដោយ ខ្លួនមិនចេះជិនឆ្អន់សោះ នៅមានសេចក្ដីប្រតិព័ទ្ធដូចមិត្តសំលាញ់ជានិច្ច ។

កុមារគិតក្នុងចិន្ដាថា ៖ ឱភូមិកំណើតអើយ !នៅកំបាំងតែដងអូរពីរ សង្កាត់ប៉ុណ្ណោះ ក៏នឹងដល់ហើយ ! ។

រទេះភ្លើងបានចាប់បរទៅទៀត ។ ពួកកូនសិស្សក៏នាំគ្នារៀបហិបរៀបអីវ៉ាន់ព្រោះនៅតែ ១៥ គីឡូទៀតនឹងដល់ផ្ទះហើយ ។ មានខ្លះដែលជាអ្នកថ្ពិតផ្ចង់ខាងរាងកាយបានចូលទៅក្នុងបន្ទប់ទឹកដើម្បីលាងមុខ សិតសក់ សំរួលមួកលើក្បាលទាញខ្សែក្រវ៉ាត់ហើយដកវែនតាខ្មៅមកពាក់ ។

ប៊ុន - ធឿន គឺជានាមនៃកុមារដែលមានមុខក្រៀមក្រំដកសំបុត្ររទេះភ្លើងមកកាន់នៅដៃ ហើយទាញវ៉ាលីស្បែកដែលសឹកដាច់ដោយដំណើរញយៗមកដាក់ខាងខ្លួន ។ នៅពេលដែលបានជិតមកដល់ក្រុងជាទីស្នេហាបំផុត អ្នកដំណើរនេះ ក៏ហាក់ដូចជាព្រួសរបេះដូងខ្លួន យោលរិតតែញឹកញាប់ឡើង ។

ផុតដំនាក់អូរដំបងហើយ ... ឆ្លងស្ពានដែក ... ឈប់បន្តិចនៅជិតវត្តកណ្ដឹង ... ផ្លូវរទេះភ្លើងកោងវាងទៅខាងវាលស្រែ ត្រើយខាងឆ្វេងនៃស្ទឹងសង្កែ ។ គុកក៏ត្រដាងជញ្ជាំងប្រះផេះ ... ផ្ទះនិងរោងជំនាងផ្សេងៗ នៃក្រុមរទេះល្បឿនយន្ដថយ ...ថយស្ថានីយ៍ !មនុស្សខ្មៅមីរនៅចាំទីនោះ ។ អ្នកដំណើរទាំងអស់គ្នាក្រោកស្រឈរមើល ។



ហ្វ្រាំងស្រែករថភ្លើងក៏ឈប់ទន្ទឹមនឹងស្ថានីយ៍ ៖ ខ្លះស្រែកហៅ ខ្លះសើច ខ្លះនិយាយកោកកាក អ្នកដំណើរ ប្រជ្រៀតគ្នា ដើម្បីចុះពីលើយានព្រោងព្រាត ។

ប៊ុន - ធឿន ទាញមួកមកពាក់ កញ្ឆក់វ៉ាលីរបស់ខ្លួនមកកាន់ ចាប់ដៃលាពួកមិត្តពីរបីនាក់ ហើយក៏ញែកពពួកមនុស្សដើរតំរង់ទៅអ្នកចាំទ្វារ ។ ដល់ហើយក៏បង្ហាញសំបុត្រខ្លួនឲ្យគេកត់សំគាល់ រួចក៏ឡើងជិះក្នុងរ៉ឺម៉កមួយ ទើបនិយាយប្រាប់អ្នកដែលធាក់ថា : ជូនខ្ញុំទៅកំពង់ព្រះ ។

ផ្លូវពីក្រុងបាត់ដំបងទៅភូមិកំពង់ព្រះ ជាផ្លូវអាណានិគមទី ១(ផ្លូវជាតិលេខ៥) ដែលជាគមនាគមន៍ ឆ្ពោះទៅកាន់ក្រុងភ្នំពេញ ផ្លូវនេះចាក់ជ័រស្អាតរាបធេង ។

រ៉ឺម៉កដែល ប៊ុន - ធឿន ជិះមិនយូរប៉ុន្មានក៏រត់ផុតគេហដ្ឋានអ្នកស្រុកក្រុងអស់ ។ មាគ៌ានេះមិនសូវស្ងាត់ទេ គេតែងជួបនឹងរទេះគោ អ្នកថ្មើរជើង អ្នកជិះចក្រយានទៅមក តែដោយប៊ុន -ធឿន ធ្លាប់ឮសួរសំរែករទេះភ្លើង ឮសំដីពួកម៉ាកពីមុនមកផ្លូវនេះក៏ហាក់ដូចជាមានសភាពស្រងេះស្រងោច រឹងរិតតែធ្វើឲ្យអ្នកដំណើរយើងខ្លោចផ្សាក្នុងចិត្តក្រៃពេក ។ ទុក្ខដែលក្រាបងំកាលដែលជិះរទេះភ្លើង ឥឡូវក៏បែរទៅជាជោរជន់ដល់ចំពង់ក ។

ប៊ុន - ធឿន លូកយកសំបុត្រដែលនាងសោភ័ណជាប្អូនបង្កើត បានផ្ញើទៅឲ្យនៅថ្ងៃមុនដែលខ្លួនចេញពីក្រុងភ្នំពេញមកមើលឡើងជាថ្មីម្ដងទៀត ។ សារនោះមានសេចក្ដីថា ។

អ្នកបង ! ខ្ញុំមិនហ៊ានលាក់ មិនប្រាប់អ្នកបងពីរឿងយើងមានគ្រោះថ្នាក់ ទុក្ខភ័យយូរទៅទេ ក្រែងបងនិន្ទា ថាប្អូនធ្វេសប្រហែស ។

បងគង់បានជ្រាបតាមសំបុត្រខ្ញុំពីថ្ងៃមុនៗ មកស្រាប់ ហើយថាលោក ឪពុកយើងគាត់បានផ្ទុកស្រូវនឹង ទូកប៉ុកចាយមួយចំណុះមួយហ្មឺនថាំង ដើម្បីនឹងនាំចុះទៅក្រុងព្រៃនគរតាមផ្លូវទន្លេសាប ។ ខ្ញុំទើបបានដំណឹងច្បាស់ថា ទូកស្រូវ នោះឥឡូវត្រូវខ្យល់ព្យុះ

បោកលិចកណ្តាលទន្លេទៅហើយ គេគ្មានសង្ឃឹមថា នឹងស្រង់យកស្រូវបានវិញខ្លះទេ ។ មុខតែខាតធំហើយគ្រានេះ ។

ប៊ុន - ធឿន កាលបើនឹកឃើញសេចក្តីសំបុត្រនេះហើយ ក៏សែនតក់ស្លុតក្នុងស្មារតី ។ សេចក្តីបំណងដែលខ្លួនបានគិតទុកទាំងអម្បាលម៉ាន ក៏រលាយដូចជាអំបិលត្រូវទឹក ។ ឱអញអើយ ! ម្ល៉េះសមនឹងត្រូវចាកចោលវិទ្យាល័យ ដើម្បីនឹងមកជួយកម្លាំងឪពុកម្តាយវិញ ។

ឪពុកម្តាយប៊ុន - ធឿនដែលមានធនធានបន្តិចបន្តួច បានខំត្រដេត្រដរប្រមូលប្រាក់យកទៅទិញស្រូវដាក់ទូកទៅលក់ ហើយថែមទាំងមានចងការប្រាក់គេខ្លះផង ។ បើប្រសិនជាគាត់លក់ទ្រព្យរបស់ ដីស្រែខ្លះទៅ ដើម្បីនឹងសងជំពាក់គេ ក៏មុខជាមិនសេសសល់ប៉ុន្មានឡើយ ?

ឱគំនិតដែលតែងធ្វើឲ្យស្រម៉ៃឃើញខ្លួនទៅរៀនឯប្រទេសក្រៅ ឲ្យបានជ្រៅជ្រះឱ ! ពាក្យដែលសច្ចាថា ប្រុងនឹងចិញ្ចឹមគូសង្សារឲ្យបានសុខសំរាន្ត ឱឪពុកម្តាយអើយ ខ្ញុំសែនលំបាក !...

អន្លង់វិល ជ្រនឹក ស្វាយកង់ .. រឺម៉ករត់កាត់ភូមិដែលរាយនៅតាមថ្នល់ ហើយដែលមាននាមជាប់ក្លិនដីក្រអូបឈ្ងួល ។ ប៊ុន -ធឿនមិនបានគយគន់មើលសោះទេ ព្រោះចិត្តនៅជំពាក់ខ្វល់តែនឹងសេចក្តីតោកយ៉ាកមួយមុខប៉ុណ្ណោះ ។

# ២

រាត្រីស្ងាត់ ។ ពន្លឺអគ្គិសនីដែលបំភ្លឺផ្លូវថ្នល់ ចោលរន្ទះពណ៌មាសទៅក្នុងទឹកពណ៌ខ្មៅនៃស្ទឹងសង្កែ ដែលហូរត្រកួញខ្នាញ់ ។

ម៉ោង ១០ យប់ហើយ ។ នៅត្រើយខាងកើត ចង្រិតយំមួយៗ ហើយយូរៗម្ដងមានរ៉ឺម៉ករត់រ៉ោឆ្លងស្ពានដែក ដឹកនាំអ្នកដែលត្រឡប់មកពីអាស្រ័យបបរសាមចូក នៅទីផ្សារវិលទៅកាន់ភូមិឋានវិញ ។

នៅតាមមាត់កំពង់ ដែលមានជួរដើមអំពិលធំត្រឈឹងត្រឈៃជាលំអ ពួកក្មេងកំលោះ តែងមកប្រជុំគ្នានៅអង្គុយលើរានតូចៗ ដើម្បីយករំហើយ ហើយនិយាយកំសាន្តរទូៗ ។

នៅភូមិវត្តពោធិក្នុង ត្រង់កំពង់ចំឡងឆ្ពោះទៅសាលារៀន ក៏មានកូនរានមួយជ្រកក្រោមអំពិលផ្អែមមួយដើមដែរ ។ តែដោយភូមិនេះ ពុំមានក្មេងកំលោះដូចភូមិឯទៀត កូនរាននេះក៏នៅទំនេរ ឥតមាននរណាមកអ្វីអែឡើយ ។

នៅយប់ដែលយើងដំណាលរឿងនេះ បើប្រសិនជាមានអ្នកដំណើរណាមួយមកឈប់ អង្គុយលេងនៅលើរានអំពិលផ្អែម គេនឹងឮសំឡេងនារីពីរោះក្រអៅ អណ្ដែតចេញមកល្វើយៗ ពីផ្ទះមួយដែលមានព្រឹក្សាដុះគ្របជុំវិញ ។ ឱសំឡេងអើយ ដែលរសាត់មកតាមវាយោជាមួយនឹងពិដោរ ក្រអូបត្រជាក់នៃផ្កាម្លិះ និងកុលាប ! ឱសំឡេងអើយថ្លាដូចចរណៃ គួឲ្យពិសម័យដល់ម្ចាស់សំឡេងនេះពន់ប្រមាណ ។

អ្នកដំណើរ កាលបើបានស្ដាប់សំឡេងនេះហើយ ក៏មិនងាយនឹងដកខ្លួនចេញពីរាននោះរួចទេ ព្រោះកម្រណាស់ និងមានសំណាងបានស្ដាប់សំឡេង ដែលមានឱជារសយ៉ាងនេះឡើយ !



បើប្រសិនជាអ្នកដំណើរនោះ ឆ្ពោះភក្ត្រមើលត្រង់ទៅខាងកើតក៏នឹងឃើញពន្លឺចង្កៀងចាំងចេញ តាមប្រឡោះស្លឹករុក្ខជាតិ ហើយនឹងឃើញមាន ផ្លូវមួយក្រាលឥដ្ឋ នាំជំហានទៅដល់ជណ្ដើរនៃ គេហដ្ឋានមួយដែលសង់ជារោងដោយ ដំបូលប្រក់ក្បឿង ជញ្ជាំងក្ដារឥតលាបថ្នាំ ដែលប្រែសំបុរទៅជាប្រផេះ ដោយត្រូវភ្លៀង និងត្រូវថ្ងៃ ។ នៅយ៉ខាងមុខដែលភ្ជាប់ និងរានហាល មានសង់ហោណាំង ១ ប្រក់ស័ង្កសីនិងមានបន្ទះឈើ ជាចរឹងព័ទ្ធពីខាងមុខ ។ នៅទីនេះមានក្ដារជៀមួយធ្វើពីខ្លឹមក្រកោះខ្មៅរលើប ។ អ្នកម្ចាស់ផ្ទះមុន និងបិទទ្វារដេក តែងមកសន្ទឹងយករំហើយនៅកន្លែងនេះ ។

គេហដ្ឋានដ៏មានរបងស្លុកស្គុម្ពតែងស្ងាត់ជ្រងំ ដោយមានតែមនុស្សស្រីបីនាក់ឋិតនៅ ។

យាយនួនមានអាយុ ៥០ឆ្នាំផ្លាយហើយសក់ស្កូវមួយៗ ហើយកោខ្លី ដោយគាត់កាន់ឧបោសថមិនដែលខានឡើយ ។ នេត្រគាត់ដែលមានពន្លឺថ្លាយង់ ហើយជ្រកនៅក្នុងរង្វង់ព្រមទាំងរង្វង់ថ្គាមមាំ យ៉ាងរឹងប៉ឹង សំដែងឲ្យយល់ថា ស្ដ្រីនេះជាអ្នកចិត្តរឹងរូសមានៈណាស់ ។ បើគំនិតគាត់បែរទៅចាប់អ្វីហើយ គ្មាននរណាងាយនឹងដកគំនិតនោះយកមកបានទេ ។ តាំងតែប្ដីគាត់ស្លាប់ចោលទៅកាលណា គាត់លះបង់ជំនួញជួញប្រែទាំងអស់ ។ គាត់ខំតែការពារ ធនធានដែលមានទាំងប៉ុន្មានទុកឲ្យកូនស្រីគាត់ ដែលគាត់មានសេចក្ដីប្រតិព័ទ្ធ លើសលប់ជាងអ្វីៗទាំងអស់ ។

នាងវិធាវី ជាបុត្រីយាយនួន ។ នាងចំរើនវ័យបាន ១៧ឆ្នាំហើយ ។ នាងមានរូបឆោមលោមពណ៌ស្រស់ចំប្រប់រាងរៀវទន់ភ្លន់ មុខមូលវែង ហើយទុកសក់ប្រះស្មាខ្មៅញាប់ ។ នាងជាអ្នកសុភាព ស្ដាប់ដំបូន្មានម្ដាយនាងជាដរាប ។ កាលដែលនៅពីតូច នាងបានទៅរៀនអក្សរនៅសាលាវត្តពោធិវាល ។ គ្រូនាងតែងសរសើរពី ប្រាជ្ញារបស់នាង ។ លុះនាងបានពេញជំទង់ហើយ ម្ដាយនាងឲ្យឈប់រៀន ។ ដូច្នេះនាងក៏នៅកាន់កាប់ការតែក្នុងផ្ទះទៅ តែបើមានពេលទំនេរនាងតែងទៅសិក្សារៀនភាសាសៀម និងរៀនចាក់ជុលជាមួយគ្រូស្រីម្នាក់ ដែលនៅជិតផ្ទះនាង ។ មិនបានប៉ុន្មានខែក្រោយមក នាងក៏ចេះ

មើលសៀវភៅរឿងសៀមបាន ។ ឯបង្អួចផ្ទះ ស្រោមខ្មើយសោត ក៏មានក្បាច់ភ្ញីលំអឡើងដោយស្នាដៃនាងក្នុងការអញ្ចូល ។

អ្នកផ្ទះទីបី គឺយាយផៃ ។ គាត់បាននៅបំរើគ្រួសារយាយនួននេះ តាំងតែពីមុនសម័យដែលនាងវិធារី មកចាប់បដិសន្ធិ ។ គាត់មានអាយុចាស់ជាងយាយនួនទៅទៀត ស្បែកគាត់ក៏សឹងស្វិតជ្រីវ សក់គាត់ក៏សឹងស្កូវស្ទើរគ្មានសល់មួយសរសៃទៅហើយ ។ នាងវិធារី តែងរាប់អានគាត់ដូចជាសាច់ញាតិពេញទី ។ មួយទៀត យាយផៃគាត់ក៏មិនចង់ដើរទៅណាឡើយ ព្រោះគាត់ធ្លាប់បីបមនាងវិធារី ហើយធ្លាប់ស្រឡាញ់តាំងតែពីកូនង៉ាមក ។ គាត់ហៅ យុវតីនេះថា នាងតូចៗ ដូច្នេះ ។

នៅយប់ដែលយើងពណ៌នានេះ យាយនួនគាត់មានកង្វល់ក្នុងចិត្ត ហើយគាត់បានបបួលកូនកាត់ ឲ្យមើលក្រាំងព្រះលក្ខិណវង្សគ្រាន់តែអផ្សុក ។

នៅពេលនោះ ចង្កៀងធូបមួយអុជដាក់ចំរើនលើក្បាលដំណេកនៃនាងវិធារី ។ នារីនេះស្លៀកសំពត់ខ្មៅ ពាក់អាវព្រៃសាច់មំដួពណ៌កុលាប ហើយបើកាលណានាងយារដៃឆ្វេង បើកសន្លឹកក្រាំងម្តងៗ ឡើងចិញ្ចៀនពេជ្រទាំងគ្រាប់ត្បូងមួយ ដែលជាគ្រឿងលំអនៃដៃនាង ក៏ចេញភ្លើងភ្លឺព្រោងព្រាយ ។ នាងអានរឿងព្រះលក្ខិណវង្សធ្វើបទបញ្ចេញសំឡេង មូលក្រអៅពិរោះឥតឧបមា ។ គឺសំឡេងនេះហើយ ដែលអ្នកដំណើរបានស្តាប់ឮល្វើយៗ ពីផ្លាមាត់កំពង់ ។

ពេលនេះយាយនួន មានមុខស្ងួត ដេកនៅស្ងៀមអែបនៅកៀនបុត្រីគាត់ ។ ឯភ្នែកគាត់សំឡឹងដោតពិតានខ្ទាប់ធ្វើឲ្យយល់ថា វិញ្ញាណស្ត្រីនេះអណ្តែតអណ្តូងទៅក្នុងគំនិតអ្វីមួយ ដែលមានសណ្ឋានកណ្តាញ់ចាក់ស្រែះ ដូចអំបោះ ដែលសំផុរហើយរកដើម រកចុងមិនឃើញជាពុំខាន ។

ចំណែកយាយផៃវិញ គាត់អង្គុយត្របោមជង្គង់ ខ្នងផ្អែកនាជញ្ជាំង ហើយស្តាប់ធ្វើមាត់ប្រហើរ ។ លុះមើលដល់ត្រង់ព្រះលក្ខិណវង្ស ជឿតាមពាក្យក្លែងនាងយិស៊ុន



ហើយប្រើឲ្យពេជ្ឈឃាត យកចៅព្រាហ្មណ៍ទៅសំលាប់ យាយផៃគាត់ជូតទឹកភ្នែកយ៉ាងញឹកញាប់ ។ លុះដល់គេបណ្តើរឲ្យនាងព្រាហ្មណ៍កេសរ ស្រែកអាក្រោសតាមផ្សារ យាយផៃគាត់ខឹងខ្លាំងណាស់ទប់មិនបានក៏ស្ទុះក្រោកឈរឡើងហើយស្រែកថា :

អញថាហើយ ! ....ថាកុំ ឲ្យមកតាម ... ប្រុសឥឡូវតែយ៉ាងនេះឯង ! បានថ្មីចោលចាស់ ឥតពិគ្រោះពិចារណាទេ !

ឮសំដីនេះហើយ នាងវិធារីដែលកំពុងជក់តាមរឿង ក៏បែរភក្ត្រមកមើលឃើញយាយផៃ គាត់ស្ទុះក្រញេងក្រញាងដូច្នោះ នាងក៏ញញឹមសើចបញ្ចេញធ្មេញថ្លាដូចផ្កាម្លិះ ហើយសួរទៅដោយសំដីផ្អែមថា :

- អីម៉េច ម៉ែផៃ !

ស្ត្រីនេះ កាលបើឮសំដីនេះហើយ ក៏ភ្ញាក់ភ្ញារដឹងខ្លួន ដូចគេទើបក្រោកពីដេក ។ នៅស្រឡាំងកាំងមួយសន្ទុះ ទើបឆ្លើយតបថា :

- អត់ទោសឲ្យខ្ញុំចុះនាងតូច ខ្ញុំខឹងណាស់ ខឹងនឹងមនុស្សដែលធ្វើការអ្វីមិនមានពិចារណា រករាក់ជ្រៅវែងឆ្ងាយសោះ ។

យាយនួន លុះឮវាចា យាយផៃថាដូច្នេះ ក៏ភ្ញាក់ខ្លួនព្រើតស្ទុះក្រោកអង្គុយឡើងហើយនិយាយថា :

- អាវីកូន មើលប៉ុណ្ណឹងចុះ យប់ក្រៃលម្មរកដេករកពួនហើយ ។ កុំភ្លេចថាយើងត្រូវក្រោកពីព្រឹកនឹងរកធ្វើការធ្វើងារនឹងគេ ។

នាងវិធារីឮហើយ ក៏ម៉ឺម៉ាក្រោកអង្គុយ យកដៃក្បិតសក់បិទក្រាំង ហើយកាន់ចង្កៀងចូលទៅខាងក្នុង ។ យាយផៃគាត់ក៏ជញ្ជូនប្រអប់ស្លា និងផ្តិល ដែលនៅរាយខាងក្រៅដាក់ទៅខាងក្នុងផ្ទះដែរ ។

បន្តិចក្រោយមក គន្លឹះទ្វារក៏ស្រែកគ្រាំងៗ ។ នាងវិធារីផ្លុំភ្លើងពន្លត់ ហើយប្រវាចូលទៅនិទ្រា ប្របនឹងមាតានាង ។

- អាវី កូនឯងងុយដេកហើយឬនៅ ?
- នៅទេម៉ែ តើម៉ែមានការអ្វី ?
- គ្មានការអ្វីធំដុំទេ ម៉ែចង់និយាយនឹងឯងបន្តិច ។ ឯងស្គាល់ ប៊ុន -ធឿនឬទេ ?

នាងវិធាវី កាលបើឮឈ្មោះបុរសឡើង ក៏ព្រឺព្រួចសប្បាយមួយសន្ទុះ ។ តែលុះនឹងឃើញផ្សេងៗ ក៏មានភ័យតក់ស្លុតទៅវិញ ដោយមានបារម្ភក្រែងមានគ្រោះកាចយ៉ាងណាមកបៀតបៀនដល់មិត្តនាងក៏មិនដឹង ។ នាងខំសង្កត់វិតក្កហើយឆ្លើយថា :

ម៉ែ ! ខ្ញុំចាំមិនភ្លេចទេ ពីដើម បង ធឿនគាត់តែងនាំខ្ញុំលេងបាយឡុកបាយឡ ។

- អើឯងដឹងរឿងប៊ុន -ធឿននេះ ! កាលឪពុកឯងគេនៅរស់ គេរាប់អានគ្រួសារប៊ុន - ធឿននេះណាស់ ។ ឪពុកឯងនិងចិកប៊ុន - ថន ឪពុក ប៊ុន- ធឿននេះជាក្លើម្រាក់ចិត្តមួយនឹងគ្នា រកស៊ីមានបានជាមួយគ្នាហើយ ...(ត្រង់នេះយាយនួនគាត់ឈប់អាក់មួយសន្ទុះ ហាក់ដូចរកពាក្យនិយាយគ្មាន) ...ហើយបាននិយាយផ្តែផ្តាំទុកដាក់ឯងនេះជាគូនឹងប៊ុន-ធឿន ដល់កាលណាចៅប៊ុន ធឿនជាប់ឌីប្លូម ។ បានជាឪពុកឯងហ៊ានប្តេជ្ញាយ៉ាងនេះ ព្រោះសម្លឹងឃើញចិកប៊ុន- ថន មានទ្រព្យធនធានល្មមចែកកូនគេឲ្យស្គាល់តែសេចក្តីសុខបាន ។ ឥឡូវនេះកូន ម៉ែពិបាកចិត្តពេក ចិកប៊ុន-ថនធ្លាក់ក្រដាបខ្លាំងណាស់ទៅហើយ ... ។
- ឱពុទ្ធោ ! ខ្ញុំអាណិតណាស់ !

យាយនួនធ្វើហាក់ដូចជាមិនឮសំដីបុត្រីគាត់ ហើយក៏តថាទៅទៀតថា :

- ពីឆ្នាំមុនៗនេះចិកប៊ុន -ថនគាត់ជួញស្រូវចេះតែខាតសម្បត្តិ គាត់ចេះតែរបេះទៅៗ ។ នៅក្នុងវស្សានេះគាត់បានខ្ចីប្រាំងបាំង (ធនាគារ) ចំនួន ១០.០០០ រៀល ទិញស្រូវផ្ទុកទូកប៉ុកចាយមួយ ដឹកចុះទៅព្រៃនគរតាមទន្លេសាប ។ ឥឡូវនេះកូនអើយ មានព្យុះបោកទូកនោះធ្លាយលិចកណ្តាលទន្លេហើយ... ។

កន្ទុយពាក្យយាយនួន រលាយសូន្យក្នុងផែនស្ងប់ស្ងៀមនៃរាត្រី ។



នាងវិធាវីសែនខ្លោចផ្សាក្នុងចិត្ត ដោយនឹកអាណិតដល់ប៊ុន - ធឿន ។ បើប្រសិនណាជានាងមានធនធានជាកម្មសិទ្ធិខ្លួនឯងវិញ ម៉្លេះសមនាងរត់ទៅជួយគ្រួសារដែលរងគ្រោះនេះឲ្យផុតពីសេចក្តីទោសទុក្ខ ... បើនឹងសំឡឹងទៅចិត្តម៉ែខ្លួន ? ...នាងក៏គ្មានរំពឹងសោះឡើយ ។

យូរបន្តិចមក យាយនួននិយាយខ្សាវៗតទៅទៀតថា :

- ទ្រព្យសម្បត្តិ ឪពុក ប៊ុន - ធឿន រលាយអស់រលីងហើយ ។ គ្រឿងមាសប្រាក់កែវកង និងស្រែភ្លឺ មើលទៅក៏លក់បញ្ចាំគ្មានសល់ ដើម្បីយកប្រាក់សងបាំង និងសងគេ អ្នកដទៃឯទៀតផង ។ អស់រលីងហើយ មុខតែវេទនាពុំខាន! ម៉ែមិនដឹងគិតធ្វើដូចម្តេចទេ ។ នែ៎កូន អញមានចិត្តគិតឯងយ៉ាងបំផុត ប្រាក់កាសអញមិនមានក្រាស់ក្រែលប៉ុន្មានទេ ល្មមគ្រាន់តែទុកឲ្យឯងមិនព្រួយលំបាកទៅថ្ងៃក្រោយប៉ុណ្ណោះ ។ ឥឡូវប៊ុន- ធឿនក្រហើយ ។

ម៉ែមានប្រសាសន៍យ៉ាងនេះមិនត្រូវទេ បងធឿនធ្លាក់ក្រខាងទ្រព្យធនមែនពិតតែគេនៅមានសម្បត្តិមួយយ៉ាងទៀតប្រពៃណាស់ គឺចំណេះវិជ្ជា ។ បើកាលណាគេប្រឡងជាប់ឌីប្លូមហើយ ...

ត្រង់នេះយាយនួនគាត់នឹកក្តាញ់នឹងសំដីកូនគាត់ពេក គាត់ក៏បញ្ចប់សេចក្តីដោយពាក្យចំអកទៅវិញថា :

- គេដើរលេងប៉ោឡែប៉ោឡោ គេដឹកស្រាស្រវឹងងុល គេដើរចោលប្រពន្ធកូនទុកឲ្យដេកត្រាំទឹកភ្នែកនៅផ្ទះ !
- ម៉ែខ្ញុំស្គាល់ចិត្តប៊ុន - ធឿន តាំងពីតូចដូចគ្នាមក ។ គាត់មិនមែនជាមនុស្សខូចកាចដូចម៉ែថានោះទេ ។
- នរណាដឹង ? នរណាមើលធ្លុះ ? ម៉ែយល់គំនិតកូនឯងអស់ហើយ ។ កូនឯងនេះមានចិត្តចង់ពឹងផ្អែកទៅលើប្រាក់ខែឌីឌីប្លូម !

សាមសិបឆ្នាយរៀល ! ធ្វើដូចម្ដេចក៏ស៊ីមិនគ្រាន់ដែរ ។ នេះថាគ្មានជំពាក់ ភ្ញាក់អ្វីផង ។ បើប្រសិនជាមានជាប់ជំពាក់គេទៀត កូនឯងមុខជាតោកយ៉ាកពុំខាន ។ ទ្រព្យអ្វីដែលម៉ែនឹងចែកឲ្យកូនឯងទាំងប៉ុន្មានទៅ មុខជាប្ដីឯងយកទៅសងបំណុលគេអស់ ។ ឱកូនអើយ ! ជឿម៉ែចុះ ក្នុងលោកនេះបើមានសម្បត្តិហើយ សេចក្ដីទុក្ខសោកនានា ឥតមកបៀតបៀនបានឡើយ ។ ម៉ែយល់ថា ប៊ុន-ធឿនជាមនុស្សមានកម្មវេរាក្រាស់ក្រៃ មិនមែនជាគូគ្រងរបស់កូនឯងទេ ។ ដូច្នោះហើយ បានជាទេវតាដែលថាំរក្សាកូនឯងលោកនាំបង្កើតហេតុភេទឲ្យឃើញថាកូនឯងនេះ គ្មានចំណងនិស្ស័យនឹង ប៊ុន-ធឿនសោះទេ ។

យាយនួន គាត់ឈប់មួយលើក ឯនាងវិធាវី ក៏នៅស្ងៀមឡឹនឡង់ ។ មួយស្របក់ក្រោយមក ទើបគេឮមាត់ម្ដាយនាងនិយាយតទៅទៀត :

- កូនអើយ ឯងកុំអាក់អន់ចិត្ត ចូរនាងរក្សាចិត្តនាងឲ្យហ្នឹងហ្ន បំភ្លេចចោល ប៊ុន ធឿន ចោលទៅ ។ ដល់ថ្ងៃក្រោយទៅ លុះនាងបានប្រកបដោយតែសុវត្ថិភាព និងសុភមង្គល នាងនឹងនឹកឃើញថា ម៉ែគាត់និយាយត្រូវមែន ។

ក្នុងវេលានោះ គេឮសំឡេងស្គរនាឡិកាវាយម៉ោង ១២អធ្រាត្រ ។ យាយនួនគាត់នៅស្ងៀមលែងស្ដី គាត់ប្រែខ្លួនទៅម្ខាង ហើយនិទ្រាលក់ទៅ ។

នាងវិធាវី ខ្សឹកខ្សួលអន់អួលទឹកនេត្រាហូរល្វែងស្រប់អស់ភក្ត្រ ។ នាងគិតឃើញថា ម្ដាយនាងនិយាយខុសទាស់ច្រើនកន្លែង ។ តែនាងជាយុវតីមួយ ដែលធ្លាប់ស្ដាប់បង្គាប់ម្ដាយជានិច្ចនិរន្តរ៍ នាងមិនដែលហ៊ានតបវាចាឆ្លងឆ្លើយនឹងម្ដាយនាងដោយរឹងត្អឹងឡើយ ។ មួយវិញទៀតនាងមានខ្មាសច្រើន ។ បើកាលណាឮគេនិយាយពីគូស្រករឡើង ខេមរកញ្ញាយើងជាធម្មតាតែងតែនៅស្ងៀមមិនចរចាទេ ទោះត្រូវចិត្តរឺមិនត្រូវចិត្តក៏ដោយ ។

ប៊ុន-ធឿន ! នាងស្រមៃឃើញមុខកំលោះនេះនៅពីមុខភ្នែកនាង ។ នាងគេងជញ្ជឹងឃើញ កាលពីកុមារតូចៗ តែងលេងជាមួយគ្នា ។ នាងនឹកឃើញថា កាលដែល



ប៊ុន-ធឿនមកលានាងទៅប្រឡងឯភ្នំពេញ ហើយយប់ៗឡើងនាងតែងអុជធូបបូជាទេវតា សុំឲ្យបងប៊ុន-ធឿនបានសំរេចក្នុងការប្រឡងនេះ ។ នាងនឹកឃើញកាលដែលប៊ុន-ធឿនត្រឡប់មកពីក្រុងភ្នំពេញវិញ ហើយមានទឹកមុខរីករាយ ដោយបានជ័យជំនះក្នុងការរៀនសូត្រ ។ នាងនឹកឃើញ ព្រៃភ្លឺព្រាលដែល ប៊ុន-ធឿន ទិញមកផ្ញើនាង ។ នាងនឹកឃើញកាលដែល ប៊ុន-ធឿននិទានរឿង " ប៉ូល និង វៀហ្ស៊ីនីប្រាប់នាង" ។ ថ្ងៃនោះឯង នាងបានហៅសំឡាញ់នាងជាល្បែងថា បងប៉ូលៗ ។ ប៊ុន-ធឿនក៏ ឆ្លើយហៅនាងថា អូនវៀហ្ស៊ីនី វិញ ។ នាងនឹកដល់កាលដែល ប៊ុន-ធឿន ជិតឡើងរថយន្តចាកចេញទៅរៀនឯក្រុងភ្នំពេញ ។ ថ្ងៃនោះប៊ុន-ធឿន បានខ្សឹបនឹងនាងថា :

អូន ! បួនឆ្នាំទៀត យើងនឹងជួបគ្នាលែងឃ្លាតហើយ ។

នាងវិធាវីកន្ទក់កន្ទេញទោម្នេញ និទ្រាមិនលក់ ចេះតែប្រែបម្រះខ្លួន ហាក់ដូចពូកកន្ទេលនាងក្លាយទៅជារងើកភ្លើង ។

នៅជិតខាង យាយនួនគាត់ស្រមុកក្រោកក្រាកៗ ។ នៅខាងក្រៅផ្ទះ ខ្យល់បក់ហ៊ឺៗ បោកផាងដូងទៅលើដើមជម្ពូ ។ មាត់មាន់ក៏រងាវម្ដងៗ ល្វើយៗ ឯសំរែកខ្លែងស្រាកក៏បញ្ចេញឡើង ធ្វើឲ្យព្រឺខ្លួន ជនណា ដែលមានដំណេករឹង ។

## ៣

ភូមិកំពង់ព្រះ ជាភូមិមួយនៅចំងាយ១៥គីឡូ ពីក្រុងបាត់ដំបង ។ ថ្នល់ក្រាលដីរទៅភ្នំពេញ ពុះកាត់ភូមិនេះចំពាក់កណ្ដាល ។ អ្នកស្រុកទាំងអស់គ្នារកទទួលទានតែនឹងស្រែ និង ស្រូវប៉ុណ្ណោះ ។ នៅតាមមាត់ថ្នល់ទាំងសងខាង មានផ្ទះថ្មី ផ្ទះឈើ ប្រក់ក្បឿងជារបស់ចិនឬកូនចៅចិន ដែលមានរបរលក់ដូរទំនិញខោអាវ ម្ហូស្លា ទឹកត្រី ទឹកស៊ីអ៊ីវ ខ្ទឹម ម្រេច និងស្រា ។ នៅខាងក្រោយ ឬចំហៀងគេហដ្ឋាននេះ មានជង្រុកធាត់ៗធំៗ ។ ផលទាំងពួង ដែលកើតឡើងដោយញើស ដោយឈាមអ្នកស្រែទាំងនោះ តែងមកប្រមូលគរនៅក្នុងជង្រុកនេះ ។ ដល់រដូវវស្សាពេលដែលស្រូវតែងឡើងថ្លៃក្រឹតៗ មានរថយន្តផ្ទុក បើកចេញចូលគគ្រឹកគគ្រេងដឹកជញ្ជូនស្រូវទៅដាក់ស្ថានីយ៍បាត់ដំបង ។

នៅចុងភូមិខាងត្បូង ។ ត្រង់មាត់អូរមុខវត្ត មានផ្ទះមួយខ្ទងសង់ជារោងដោល ដីមានដំបូលប្រក់ក្បឿងដែលស្លែកាន់ ហើយជ្រកក្រោមស្វាយមួយដើមដ៏មានមែកសាខា ។ នៅទីធ្លាផ្ទះនោះឯង គេមានដាំដើមកុលាប ម្លិះ និងចំប៉ាដែលមានផ្ការរីកស្គុះស្គាយជាលំអ ហើយមានគន្លងល្វឹងល្វើយរសាត់ទៅតាមវាយោ ។ ផ្ទះនេះមានសភាពស្ងាត់ជញ្ជ្រងឥតមានមាន់ខ្គត , ទា ឬជ្រូកស្រែកដូចនៅផ្ទះជិតខាងឡើយ ។ ផ្លូវឲ្យច់មួយសម្បុរលឿងខ្ចិន សំរាប់នាំអ្នកដើរចុះពីថ្នល់ធំ ទៅកាន់ជណ្ដើរឈើដែលលាបថ្នាំពណ៌ខៀវចាស់ ។

ផ្ទះនេះនៅស្ងាត់ជ្រងំ គ្មានឮមាត់មនុស្សសោះ ឮតែនាឡិកាភ្លេងមួយដើរតិកតក់, តិកតក់ និង សូររ៉ោ ៗ នៃយន្តដេរមួយ ។ នៅជិតបង្អួចដែលបែរមុខទៅរកថ្នល់ មានយុវនារីម្នាក់ធាត់មាំ ស្លៀកសំពត់ខ្មៅចងក្បិនពាក់អាវទេសឯកស ។ អង្គុយខិតខំធ្វើការឥតមើលនាយអាយឡើយ ។ មាណវីនេះទុកសក់ប្រះស្មា ឯដងខ្លួននាងក៏ងក់ងើបៗយោលចុះឡើង ដោយជើងនាងធាក់ឈ្នាន់យន្ត ហើយបណ្ដាលឲ្យរំជួលដល់ទៅខ្សែកមាស ដែលព្យួរបន្តោងនីលមួយគ្រាប់នៅលើសុរង ។ នាងខំធ្វើការនេះខ្ជាប់ខ្ជួនណាស់ទាល់តែមានញើសគ្រាប់ល្អិតៗ ដេរដាសលើចុងច្រមុះ ។



នៅខាងស្ដាំមាត់ទ្វារ មានក្ដារជៀជំក្រាស់មួយ ដែលជូតខាត់ឡើងរលោងស្រិល ។ នៅលើក្ដារជៀនេះ បុរសម្នាក់ស្លៀកខោឡាញ់ខ្មៅ ខ្លួននៅទទេ ដេកជើងគងអន្ទាក់ខ្លា ដៃស្ដាំគងថ្ងាសនៅស្ងៀមស្ងូក ។ តើគាត់ដេកលក់ឬ ? មិនមែនលក់ទេ ព្រោះយូរៗម្ដងគាត់យកដៃស្ដាំដែលគងថ្ងាសនោះទៅស្រវាចាប់ក្រមាមួយមកបក់មូស និងរុយដែលធ្វើឲ្យគាត់មានរំខាន ។

ក្រោយពីនោះបន្តិចមក គេឃើញគាត់ប្រែខ្លួនមកខាងឆ្វេង ហើយមានសំដីយ៉ាងទន់ផ្អែម ទៅកាន់នាងក្រមុំដែលដេរយន្តថា :

- សោភ័ណ កូន ម៉ោងប៉ុន្មានហើយ ?

នារីនោះក៏ឈប់ដេរ ហើយដើរមកសម្លឹងនាឡិកាធំដែលដើរតិកតក់ !តិកតក់! ។

- ម៉ោងជិតបួនហើយចិក ។
- អើ ល្មមឈប់ដេរហើយ កូន ។ រកអុស ទឹក ដាំបាយទៅ ។
- ចាស ចាំខ្ញុំបង្ហើយអាវនេះមួយរំពេចសិន ព្រោះគេអ្នកជួលបន្ទាន់យកល្ងាចនេះ ។
- យីចុះ ប៊ុន-ធឿន វាទៅណាបាត់ទៅហ្ន៎ ?
- បងគាត់ទៅជួយស្ទូងម៉ែ ចិក

បុរសនេះ កាលបើឮបុត្រីខ្លួនថាដូច្នោះហើយ ក៏ដកដង្ហើមធំ តែនៅស្ងៀមមិនចេញស្ដីថាអ្វីឡើយ ។

ចិក ប៊ុន-ថននេះ គាត់អាយុហាសិបប្លាយឆ្នាំហើយ ។ សក់គាត់នៅខ្មៅតែគាត់ខ្ចីរូបរាងគាត់នៅរឹងប៉ឹងណាស់ មុខរាហ៍ ថ្ងាសខូលាយ ដែលមានរស្មីភ្លែកថ្លាយង់មកសំដែងអោយឃើញថា បុរសនេះជាមនុស្សចិត្តល្អ មានសន្ដោសដល់អ្នកជិតខាង ។ កាលពីមុនគាត់មានបាវព្រាវ មានញាតិមិត្រចុះឡើងកុះករណាស់ ។ ឥឡូវនេះ គាត់មានសេចក្ដីព្រួយដោយគាត់មានគ្រោះថ្នាក់ខាតក្នុងជំនួញស្រូវយ៉ាងសំបើម ។ សម្បត្តិទ្រព្យ

ខូ គ្រឿងមាស ប្រាក់ និងស្រែភ្លឺខ្លះ គាត់បានលក់យកប្រាក់សងជំពាក់បំណុលស្រេចហើយ ។ គ្រានេះគាត់នៅសល់សឹងតែសំបកផ្ទះទទេ ។ ខ្ញុំកំដរអ៊ីវាចេញទៅនៅ និងគេដទៃលើកលែងតែតាសូមួយ ដោយគាត់ធ្លាប់បំរើពឹងពាក់អាស្រ័យមកជាយូរថ្ងៃហើយ ។

សូមអ្នកអានទាំងឡាយជ្រាបថា ចិកប៊ុន-ថន គាត់មិនមែនក្រជុនដាបដល់សុំទាននោះក៏ទេដែរ ។ តែមនុស្សយើងដែលធ្លាប់មានមុខមាត់នឹងគេហើយលុះមកធ្លាក់ក្នុងអន្លង់នៃសេចក្ដីព្រួយដូច្នេះ ក៏សឹងតែមានចិត្តរំខានហ្មងសៅពន់ប្រមាណ ។

ពីដើមមក គាត់បានខ្នះខ្នែងម៉ឹងម៉ាត់ ក្នុងការវិជ្ជាជីវៈណាស់ ។ ឥឡូវ សេចក្ដីទុក្ខព្រួយធ្វើឲ្យគាត់ទន់ដៃ ទន់ជើងរកនឹកធ្វើការងារអ្វីពុំកើត ។ នាងសោភ័ណ លុះឈប់ដេរហើយក៏ដើរចូលទៅជើងក្រានហើយ កាន់ពោតមួយចានយកមកជូនឪពុក :

- ចិក នេះពោតស្ងោរក្ដៅ ៗ ចិកពិសាទៅផ្អែមល្អណាស់ ។

ចិកប៊ុន- ថន គាត់យកដៃគះចាននោះចេញ ហើយឆ្លើយថា :

- ទេកូន ឯងទុកឲ្យម៉ែ និងបងឯងស៊ីចុះ គេធ្វើការនឿយ ចិកមិនឃ្លានទេ ។

នាងសោភ័ណ មិនឆ្លើយតបថាអ្វីឡើយ ។ នាងឈរសំឡឹងមុខឪពុក ធ្វើភ្នែកឡឹងឡង់មួយសន្ទុះ ក៏ស្ទុះទៅយកក្រមាបង់កមកខ្ទប់មុខជូតទឹកភ្នែក ។

ដើម្បីនឹងបន្លប់សេចក្ដីចំបែងក្នុងចិត្ត នាងក៏យកក្អមមួយចុះទៅដងទឹកអណ្ដូងដាក់ពាង យកពូថៅពុះឧស រួចហើយបង្កាត់ភ្លើង ស្ងួដណ្ដាំទុកជូនគ្រួសារនាង ។

សែងព្រះអាទិត្យអស្ដង្គតចាំងស្លឹកដើមត្នោត ដែលដុះក្នុងខឿនវត្តឡើងក្រហមរើៗ ។ ចាបដែលសំបុកព្យួរយោងនៅចុងធាងរុក្ខជាតិ ក៏និយាយប្រឡែងគ្នាទ្រហឹងអឹងកង ។

នៅពេលនោះ ស្ត្រីម្នាក់អាយុកណ្ដាលមនុស្ស និងក្មេងកំលោះម្នាក់មុខស្ងួតស្ងប់សម្បុរស្បែកឡើងទង់ដែង ដោយត្រូវកំដៅថ្ងៃ ដើរមកពីខាងត្បូងចូលមកក្នុងភូមិ ។ មនុស្សទាំងពីរនេះស្លៀកពាក់ខោអាវធ្លុះ ហើយមានដំណើរចេងពោងដោយអស់កម្លាំងជ្រុលពេក ។



ប៊ុន-ធឿន ក្មេងកំលោះនោះឯងឈ្មោះ ប៊ុន -ធឿនដែលយើងបានស្គាល់ពីមុនមកហើយ ត្រឡប់មកពីជួយដកស្ទូងនាងង៉ាន់ជាម្ដាយ ។

ពួកកូនសិស្សទាំងឡាយក្នុងវិស្សមកាល តែងបានសំរាកសំរាន្ត លេងសើចសប្បាយ ។

មិនដូច្នោះឡើយ ប៊ុន-ធឿន គ្មាធ្វើការយ៉ាងជុនដាប ។

លុះដល់ផ្ទះហើយ ប៊ុន-ធឿន ក៏ចូលទៅផ្លាស់ខោអាវស្រែស្លៀកសារុង ទុកខ្លួននៅទទេ ទើបមកអង្គុយជិតឪពុកធ្វើមុខជូរស្ងួត ។ នាងសោភ័ណ ឃើញគ្រួសារមកជួបជុំហើយ ក៏ទៅលើកម្ហូបបាយដាក់លើក្ដារជៀ អញ្ជើញ ម៉ែ ឪ និងបងឲ្យពិសា ។ ឯខ្លួននាងក៏ចូលអាស្រ័យជាមួយដែរ ។ ដើម្បីនឹងបង្វែងផ្លូវ ពីសេចក្ដីតឹងទ្រូងចេញ នាងសោភ័ណ ក៏ធ្វើជាសាកសួរទៅម្ដាយថា :

- ម៉ែ , ម៉ែស្ទូងបានប៉ុន្មានហើយ ?

អឺ កូនបានស្រែពីរហើយ ។ ប៊ុន-ធឿនចេះស្ទូងរហ័សណាស់ ។ អ្នកផងគេតែងនិយាយថា ក្មេងដែលបានទៅរៀនសូត្រនៅសាលាបារាំងច្រើនស្អប់ខ្ពើមការងារស្រែចំការ ។ បងឯងនេះធ្វើឲ្យឃើញថា និយាយដូច្នោះជាការមិនពិតឡើយ ។

ប៊ុន-ធឿន ស្ដាប់ពាក្យម្ដាយសរសើរខ្លួនដូច្នេះ ក៏ញញឹមទាំងស្រពោន ហើយតបទៅថា :

- ម៉ែអើយ កុំអួតខ្ញុំខ្លាំងពេក ។ ពីដើមខ្ញុំមានសេចក្ដីរំពឹងថា ខ្ញុំរៀនឲ្យបានចេះដើម្បីកុំឲ្យស្គាល់ក្ដៅ ស្គាល់នឿយដោយហាលថ្ងៃ ។ ឥឡូវនេះ បំណងនេះរលាយសាបសូន្យទៅហើយ មានតែខំធ្វើស្រែទៅ ។ ម្យ៉ាងទៀត ខ្ញុំចូលចិត្តនៅស្រុកស្រែ និងធ្វើការក្នុងស្រែណាស់ កាលដែលខ្ញុំនៅ កុល្លែហ្ស៊ីងនោះថ្ងៃអាទិត្យឡើង ខ្ញុំតែងចេញពីក្រុងភ្នំពេញទៅមើលគេធ្វើចំការ ច្បារដំណាំ ។ ទោះយើងមានទោសទុក្ខធ្ងន់យ៉ាងណា បើយើងបានឃើញ ស្រែចំការហើយ សេចក្ដីសៅហ្មងនោះ និងបានស្រយាលជានិច្ច ។

នាងសោភ័ណតប :

- បើដូច្នោះមែន បងស្អែកនេះខ្ញុំទៅលេងស្រែផងបានឬទេ ?

- មានកើតអីអូន ។

យប់គ្រាន់បើហើយ ។ ចិកប៊ុន-ថន គាត់ហៅបុត្រគាត់មកនិយាយតែពីរនាក់ :

- កូន ឪពុកដឹងចិត្តកូនឯងចង់លែងរៀន ដើម្បីមកជួយធ្វើការឪពុកម្ដាយ ។ គំនិតនេះជាការគាប់ប្រសើរហើយ តែចិត្តឪពុកមិនចង់ឲ្យឯងឈប់រៀនទេ ស៊ូត្រដេត្រដរផ្ដល់សោហ៊ុយឲ្យឯងរៀនលុះត្រាតែបានឌីប្លូម ។

- ខ្ញុំបាទយល់ឃើញថា ចិកមានប្រសាសន៍យ៉ាងនេះ ដោយស្រឡាញ់កូន មិនចង់ឲ្យកូនមកនឿយហត់ ។ ខ្ញុំគិតថា ចិក និងម៉ែ សុទ្ធតែបានបង្ហូរញើស ព្រួយកំឡាំងដោយសារខ្ញុំយូរមកហើយ ។ សម័យនេះ ខ្លួនចិកទ្រុឌទ្រោមថមថយជាងពីដើមគួរណាស់តែខ្ញុំមកជួយកំឡាំងវិញ ។

- ប៊ុន- ធឿន កុំប្រកែក ។ ចូរឯងខំតែរៀនសូត្រទៅចុះឪពុកមិនទាន់ដល់ថ្នាក់សុំទានគេ នៅឡើយទេ ។

ចិកប៊ុន-ថន ថាតែប៉ុណ្ណោះហើយ គាត់ក៏ដើរចេញទៅ ។

រាត្រីលាតសន្ធឹងស្បៃខ្មៅ លើធម្មជាតិ ដែលស្ងប់ស្ងៀមជញ្ជ្រង ។

ចង្កៀងប្រេងកាតមួយមានពន្លឺញ័ររព្រឹតៗ នៅបំភ្លឺផ្ទះធំល្វឹងនៃចិក ប៊ុន -ថន ។

ប៊ុន - ធឿនអង្គុយសញ្ជឹងសញ្ជប់ភ្លេចសេចក្ដីនឿយហត់ពីថ្ងៃ ។

សំឡេងខ្លុយមួយពិរោះគ្រលួចក្នុងផែនសន្ធិយា ហើរកាត់មែកស្វាយមកអង្អែលបបោសសោតវិញ្ញាណនៃជន ដែលមិនទាន់ដេកលក់នៅឡើយ ។

ឯដួងវិញ្ញាណប៊ុន-ធឿន វិលចុះ វេឡើង មិនមានទៅចាប់ឆ្ពោះលើវត្ថុអ្វីឡើយ ។ ត្រិះរិះមើលទៅឃើញថា ឪពុកខ្លួននិយាយត្រូវមែន ។ គួរតែស៊ូខំរៀនទៅចុះ គ្រាន់នឹងយកប្រាក់ខែមកជួយចិញ្ចឹមឪពុកម្ដាយ ។ ជំពូកមួយទៀត ចិត្ត ប៊ុន- ធឿន គិតមមៃដល់



នាងវិធាវីជាគូសង្សារ ។ បើប្រសិនជាខ្លួន នៅតែធ្វើស្រែយ៉ាងនេះទៅ ម្ល៉េះសមយាយទួនគាត់ផ្ដាច់ពាក្យសន្យាពុំខាន ព្រោះដឹងថាគាត់ស្រឡាញ់ថ្នមកូនគាត់ខ្លាំងណាស់ ម្ដេចគាត់នឹងឲ្យកូនគាត់មកធ្វើការនឿយហត់ជាមួយផង ។

ឈ្វេងយល់យ៉ាងនេះហើយ ប៊ុន-ធឿនក៏យកចិត្តទុកដាក់នឹងការរៀនសូត្រឡើងវិញ យប់ៗឡើង តែងអុជចង្កៀងប្រេងដូងមួយ មើលសៀវភៅ ។ ថ្ងៃៗ ឡើងទៅធ្វើការស្រែ តែងតែឆ្លៀតដាក់សៀវភៅកវីបារាំង ណាដែលជាទីគាប់ចិត្តយកទៅអាន នៅពេលឈប់សំរាកកំឡាំង ។ជួនណាអ្នកទៅឃ្វាលគោជួសតាសូឲ្យគាត់មកពិសាបាយ ។ អ្នកក៏ដេកក្រោមដើមដង្កោ ឬដើមស្ដៅ ក្បាលកើយលើក្រមាមួយដែលផ្នួលជាដុំ អ្នកមើលគោបណ្ដើរ អានសៀវភៅបណ្ដើរ ។ សព្ទឃ្លោងខ្លះពិរោះអស្ចារ្យ បណ្ដាលឲ្យអ្នកស្រមៃឃើញមុខនាងវិធាវីញញឹមស្រស់ត្រង់ប្រឡោះស្លឹករុក្ខជាតិ ។ ឱវ៍ប៊ុន-ធឿន ក៏ត្រេកត្រអាលចិត្តរីករាយសប្បាយក្រៃលែង ។ ដូច្នេះហើយ ការងារស្រែទាំងប៉ុន្មាន ក៏បាត់ធ្វើឲ្យធុញថប់ និងហត់នឿយ អស់ទៅ ។

នៅល្ងាចថ្ងៃទី ១៣កក្កដា ចិកប៊ុន-ថន និយាយទៅកាន់បុត្រគាត់ថា

- ថ្ងៃស្អែកនេះ ជាថ្ងៃបុណ្យជាតិរបស់បារាំង ។ បើឯងចង់ទៅមើលបុណ្យនោះក៏ទៅចុះ ។

នៅព្រឹកព្រហាមថ្ងៃទី ១២ ស៊ូយេត ប៊ុន-ធឿនបានតែងខ្លួនស្អាតបាត ហើយជិះទោចក្រយានតម្រង់ទៅបាត់ដំបង នឹករីករាយសប្បាយក្នុងចិត្តថា នឹងបានជួបមុខកែវសង្សាររបស់ខ្លួនពុំខាន ។

នៅគ្រប់ផ្លូវថ្នល់ មនុស្សឈ្មូនរដើរមីរ មានសភាពដូចជាហ្វូងស្រមោច ។ ពួកអ្នកស្រុកស្លៀកពាក់តាមទំនើបថ្មី ។ ឯអ្នកស្រុកស្រែបញ្ចេញ សំលៀកបំពាក់ភោរភាវគ្រប់ពណ៌ ។ តាមថ្នល់ក្រុង និងតាមបង្អួចផ្ទះផ្សារ ទង់ជាតិបារាំង-ខ្មែរបក់យោលវេរាបញ្ចេញសេចក្ដីសប្បាយរោយរាយទៅគ្រប់ទិស ។ ត្រង់មាត់កំពង់,ចំពីមុខផ្សារវិល គេមានសង់ពន្លាមួយលំអដោយ ស្លឹកទន្សែ ស្លឹកជ្រៃក្រឹម និងផ្ទាំងសំពត់ ខៀវ ស ក្រហម ។

ពួកឥស្សរជនទាំងឡាយនៃខែត្រ បានមកអង្គុយជ្រកកំដៅព្រះសុរិយោទ័យក្នុងនោះ បារាំត្រៀបត្រា។ តាមចិញ្ចើមនៃមាគ៌ាប្រជាជនខ្សៀវខ្សាឈរចាំមើល...

មានក្រុមពិជ័យសង្គ្រាមមួយកង ក្រុមរក្សាស្រុកមួយកង ស្លៀកពាក់ស ក្បាលពាក់បេរ៉េក្រហម ឬខៀវផ្ទៃមេឃ ពោះនិងកំភួនជើង រុំព័ទ្ធដោយផ្ទាំងសំពត់ពណ៌ដដែលនេះឈរតម្រៀបជាជួរឥតខ្ចោះ នៅចំពីមុខរោងបុណ្យ

ប៊ុន-ធឿន ឈរលាយឡំនឹងពពួកជន មើលទាហានលើកអាវុធគំនាប់ងាកខ្លួនហើយឈានជើងដើរស្រុះគ្នាព្រិប ដោយមានសក្តិបីបារាំងមួយធាត់ក្រអាញជិះសេះហើយធ្មើរភ្នែកក្រឡឹតក្រឡាប់យ៉ាងសំបើម ជាអ្នកបញ្ជា និងដោយភ្លេងត្រែប្រគំបន្ទរផង ។

តអំពីនោះមកប្រជាជនក៏នាំគ្នាប្រជ្រៀតមើលល្បែងផ្សេងៗ ដូចជាចងជើងក្នុងបាវឲ្យរត់ប្រណាំង ឡើងសសរលាបខ្លាញ់ ប្រកួតជក់បារី ។ល។ តែប៊ុន-ធឿនធុញទ្រាន់ពេក ក៏ចុះទៅកំពង់ចំឡង ជិះទូកដរទៅត្រើយខាងកើត ហើយដើរតម្រង់ទៅភូមិវត្តពោធិ៍ ។





# ៤

ជួនជាថ្ងៃនេះ ជាថ្ងៃពេញបូណ៌មី ។ យាយនួនគាត់ទៅកាន់ឧបោសថ ឯវត្តពោធិ៍ ។ នាងវិធាវីកាលបើម្ហូបរៀបចំដាក់ចានស្រាក់ ឲ្យម៉ែផៃគាត់លើកទៅជូន ម្តាយនាងរួចស្រេចហើយ នាងក៏ម៉ីម្នាបិទទ្វារផ្ទះ ហើយយកប្រលោមលោកសៀមមួយ កាន់ចុះទៅគេងអានក្នុងអង្រឹងមួយចងក្រោមស្វាយមួយដើម ដែលបែកមែកត្រសាយនៅកន្សៃផ្ទះនាង ។

នេត្រនាងរំពៃតាមខ្សែបន្ទាត់អក្សរសៀវភៅ តែដួងចិត្តនាងរសាត់ដោយទៅតាមខ្យល់រំហើយ ។ គ្រលីងគ្រលោងមួយគូ ដែលទុំលើមែករុក្ខា យំឆ្លើយឆ្លងគ្នា ហើយជួនកាលមានកំប្រុកលោតពីលើធាងដូងមួយ ឮសូរក្រាកៗ នាងវិធាវីកំពុងតែស្រងូតចិត្តគិត អាណិតខ្លួនពន់ពេកក្រៃស្រាប់តែស្រមៃឮសូរមនុស្សដើរលើស្លឹកស្វាយទុំ ដែលជ្រុះរោយរាយលើពសុធា ។ នាងក៏ងាកមើលទៅ ហើយក៏ញញឹមព្រាង :

- បង ! យីបង មកពីកាលណាហ្នឹង ? បងគ្មាននឹកនាដល់អូនសោះ តែម្តងហើយ ។ មកវ៉ាកងយូរណាស់ហើយមិនហ៊ានមកលេងនឹងខ្ញុំសោះ ។

ប៊ុន-ធឿន ចូលទៅជិត ហើយគំនាប់នាងដោយញញឹមស្ងួត ។

- អូនកុំនិយាយយ៉ាងនេះនាំអោយបាបនឹងទេវតា ។ បងតែងនឹកនាងមិនមានណាយសោះ តែបងឥឡូវធ្លាក់យ៉ាកចុនហើយ រវល់តែខំជួយកំលាំងឪពុកម្តាយ ។ បងឆ្លៀតឱកាសបុណ្យ ១៤ ស៊ូយេត ដើម្បីមកលេងនឹងមីងនួនហើយនិងអូនឯង ។

- ម៉ែគាត់មិននៅទេ គាត់ទៅវត្តផុតទៅហើយ ។

ដំណឹងនេះធ្វើអោយ ប៊ុន-ធឿនត្រេកអរឥតឧបមា តែខំទប់កិរិយាមិនឲ្យបញ្ចេញសេចក្តីសប្បាយឲ្យឃើញឡើយ ។

- ឱ !បងសែនស្តាយ ព្រោះបងបន្ទាន់វិលទៅផ្ទះ វិលនៅរសៀលម៉ោង ៣នេះ ។



បន្ទាន់អ្វីម្ល៉េះ ម៉េចក៏មិនចាំមើលប្រណាំងទូកសិន ខ្ញុំឮគេនិយាយថាទូកងលោកវត្តឈើខ្មៅ ឈ្មោះ "ពពកអណ្តែត" លឿនអស្ចារ្យ ។

- បងរង់ចាំមើលមិនបានទេ ។ បងសុំផ្ញើភ្នែកមួយឲ្យអូន មើលជួសបងផងបានវីទេ ?

- មិនបានទេ ! ព្រោះពេលនេះខ្ញុំគ្មានត្រេកត្រអាលអ្វីនឹងបុណ្យនឹងង៉ាននេះសោះ ។ ខ្ញុំរកតែទីស្ងាត់គិតជញ្ជឹងទើបស្រួលតាមលំនាំចិត្តរបស់ខ្ញុំ ។

ថាហើយនាងងើបមើលមុខប៊ុន-ធឿន ហើយឱនភក្ត្រចុះមិនចេញស្តី ។

ប៊ុន-ធឿនគិតស្មានដោយខុសថា នាងមានសេចក្តីជួយព្រួយនឹងការគ្រោះថ្នាក់នៃគ្រួសារខ្លួន ក៏និយាយទៅកាន់នាងថា ៖

- នែ៎អូន ! បងសុំអរចិត្តអូនហើយដែលនាងជួយព្រួយបារម្ភនោះ នែចូរនាងបាត់ភ័យទៅ ។ ថ្វីបើខ្លួនបងធ្លាក់ក្រ បងនឹងខិតខំរៀនទ្វេមួយជាពីរជាបី ។លុះបានសញ្ញាប័ត្របឋមសិក្សាជាន់ខ្ពស់កាលណា បងនឹងចេញធ្វើការហើយ... ។

ត្រង់នេះ ប៊ុន-ធឿន សំឡឹងនេត្រនាងវិធាវីដែលខ្មៅយង់ដូចត្បូងនិល ទើបចរចាទៅទៀត ។

- ហើយយើងនឹងបានសុខក្សេមក្សាន្តតទៅ ។

នាងវិធាវីឮសំដីបងដូច្នោះហើយ ទឹកភ្នែកដែលនាងខំទប់បានកុំឲ្យជោរជលកាលពីមុននោះ ក៏ហៀរហូរខ្វាយធ្លាក់មក ។ នាងប្រឹងយកកូនកន្សែងមកជូត ។

ប៊ុន-ធឿន ឃើញដូច្នោះហើយ ក៏ធ្វើភ្នែកឡឹងឡង់ :

- តើអូនមានទុក្ខយ៉ាងណា ! ប្រាប់បងផង ?

នាងវិធាវី ដោយអៀនខ្មាស ក៏មិនឆ្លើយតបចំពោះពាក្យសួរនេះទេ បែរជាស្តីថា:

- បងអើយមនុស្សយើង បើប្រាថ្នាអ្វីមួយ មិនដែលបានដូចបំណងរាល់ដងទេជួនបាន ជួនខាន ។ យើងសំឡឹងទៅមុខមិនធ្លុះសោះ ។ ស្មានជាបានស ទៅ

ជួបឯខ្មៅ ឬផ្ទុយទៅវិញក៏មានដែរ ។ អូនសូមលន់តួកាត់សេចក្តីខ្មាសជំរាបបងឲ្យជាក់ថា ចិត្តអូនមិនប្រែប្រួលពីសច្ចាដែលបានផ្ញើមកនោះទេ ។ ចិត្តអូនឥឡូវនេះមានសភាពយ៉ាងណា ទៅថ្ងៃក្រោយក៏នៅយ៉ាងនោះដែរ ។ បើទៅអនាគត យើងនឹងមានអាសន្នក្រដូចម្តេច យើងត្រូវនឹករកគ្នាជានិច្ច ។ ដូច្នេះ យើងត្រូវមានវត្ថុអ្វីកាន់ខ្ជាប់នៅខ្លួន ដើម្បីទុកជាទីនឹករលឹករបស់ជនសំឡាញ់ដែលឃ្លាតឆ្ងាយទៅ ។ ហេតុនេះ សូមបងទទួលរូបថតនេះទុកចុះ ។

ប៊ុន-ធឿនដែលស្មារតីអណ្តែតទៅឆ្ងាយ លុះឮថារូបថតដូច្នោះក៏ភ្ញាក់ខ្លួនព្រើតដាក់ភ្នែកមកមើលឃើញ នាងវិធាវីដកកូនរូបថតតូចមួយដាក់ក្នុងកញ្ចក់មូលក្រឡង់ដែលមានសរសៃមាសវង់ព័ទ្ធជាក្របជុំវិញ ។ ប៊ុន -ធឿន ក៏ទទួលយកមកគន់មើលដោយសេចក្តីប្រតិព័ទ្ធយ៉ាងចំហុត ។

- អូន បងស្តាប់អូនមិនទាន់បានទេ ។ម៉េចអូនថាខ្លាចមានភ័យភិតថ្ងៃក្រោយ ។ អូនឯងមានដឹងការអ្វីចំឡែក ចូរនាងប្រាប់បងផង ។

- ខ្ញុំមិនមានដឹងការអ្វីចំឡែកទេ ។ អញ្ជើញបងទៅដោយក្សេមក្សាន្តចុះ ។ ខ្ញុំមិនហ៊ាននៅនិយាយតែពីរនាក់នឹងបងយូរពេកទេ ខ្លាចមានពាក្យនិន្ទាទៅថ្ងៃក្រោយ ។

ថាហើយ នាងក៏ក្រោកពីអង្រឹង ប៊ុន-ធឿន ក៏ឈានជើងដើរចេញទៅ មុខស្រងូត ។

ភ្នែកនាងវិធាវី តាមមើលគួសង្ស័រ លុះត្រាតែប៊ុន-ធឿនដើរផុតឆ្ងាយទៅកំបាំងនឹងរុក្ខជាតិ ទើបនាងដាក់មុខចុះហើយដកដង្ហើមធំ ...

សែងព្រះអាទិត្យនៃវេលាល្ងាចស្លឹកល្មុត បណ្តាលឲ្យមានរស្មីភ្លឺច្រាលដូចកំទេចសុវណ្ណ ...នាងវិធាវីដែលមានភក្ត្រស្ងប់ស្ងួត នាងអង្គុយមើលធម្មជាតិ និងពពួកមនុស្សដែលដើរហូរហែ មកពីមើលបុណ្យ ១៤ស៊ូយេត ។ នៅសញ្ជប់សញ្ជឹងយ៉ាងនេះយូរបន្តិច



ស្រាប់តែយាយនួនស្លៀកពាក់ស យួរកញ្ជ្រែងស្លាដើរចូលមក ។ ឃើញកូនមុខក្រៀមក្រំដូច្នោះគាត់ក៏សួរថា :

អាវី ឯងចង់ទៅមើលបុណ្យនឹងគេហើយ ។ យប់នេះគេថា មានរបាំនៅមុខផ្ទះលោកធំល្អមើលណាស់ ។ បើឯងចង់ទៅមើលចាំអញរកគេជូន ។

នាងវិធាវីឆ្លើយយ៉ាងតិចៗ ថា :

- ទេម៉ែ ... កូនមិនចង់ទៅមើលអ្វីទេ ។

យាយនួនគាត់សំឡឹងមើលមុខកូនគាត់មួយសន្ទុះ ទើបគាត់ដើរចូលទៅខាងក្នុង ទឹកមុខគាត់មានអាការប្រែប្រួលសំដែងឲ្យឃើញថា គាត់មានមនោគតិអ្វីៗមួយពុំខាន ។

# ៥

យាយនួនគាត់ឃើញថា កូនគាត់មានអផ្សុកក្នុងចិត្ត ។ បើប្រសិនជាមានគូស្រករទៅ ហើយចេះស្រឡាញ់គ្នាផងនោះ មុខជានឹងបាត់ហ្មងសៅពុំខាន ។ បើដូច្នេះហើយ តោងគាត់រិះរកឧបាយកលផ្ដាច់នាងវិធារីពី ប៊ុន-ធឿនចេញ ព្រោះគាត់យល់ថា ការជំពាក់ពាក្យគ្នាយ៉ាងនេះ ជាឧបសគ្គមិនឲ្យអ្នកផង គេចូលមកនិយាយដណ្ដឹងកូនគាត់បានទេ ។ មិនយូរប៉ុន្មានស្រាប់តែទេសកាលណែនាំឲ្យគាត់ជួបនឹងឱកាស ដែលគាត់ខំរកនោះភ្លាម ។

យាយនួនគាត់មានសំឡាញ់ម្នាក់ ឈ្មោះយាយចាន់ ។ ស្ត្រីនេះតាំងផ្ទះនៅភូមិវត្តសង្កែ ។ មិត្រទាំងពីរនាក់នេះតែងតែទៅមករកគ្នាមិនសូវដាច់ទេ ។

មានថ្ងៃមួយ ក្រោយពីថ្ងៃដែលយើងនិទានក្នុងភាគមុនបួនខែមក គេឃើញស្ត្រីម្នាក់សក់គាត់ជ្រងអាយុប្រហែលជាង ៦០ហើយ តែងរឹងប៉ឹងនៅឡើយ ។ ដូនចាស់ដែលស្លៀកខៀនពណ៌ស្បែកតុកកែ ពាក់អាវផាប៉ាំនស ពានាក្រមាទេសឯកដែរនោះ បានបញ្ឈប់រ៉ឺម៉កនៅចំមុខផ្ទះយាយនួន ហើយគាត់ក៏ដើរចូលទៅកាន់គេហដ្ឋាននេះ ។ បន្តិចក្រោយមក គេក៏ឮសូរមាត់យាយនួនស្រែកថា :

- អារី អើយ អុំចាន់ឯងគេមកលេង ។ ឯណាប្រអប់ស្លាយកមក ។

ថាហើយ គាត់ក៏បែរមុខឆ្ពោះទៅកាន់មិត្តគាត់ :

- អញ្ជើញចាន់ ! អញ្ជើញមកលើកន្ទេលមក អង្គុយលើក្ដារមិនកើតទេ ប្រឡាក់ខៀនអស់ហើយ ។

យាយចាន់ឆ្លើយ :

- មិនអីទេ ក្ដារនេះរលីងស្រិល អង្គុយត្រជាក់ស្រួលណាស់

ខណៈនោះនាងវិធារីលើកហិបស្លាមកដាក់នៅមុខភ្ញៀវ ទើបនាងលើកដៃសំពះ



- ជំរាបសួរ អ៊ំ !

យាយចាន់ដែលភ្នែកសំឡឹងរាងកាយនាងយុវតីមិនដាច់ ក៏ឆ្លើយថា :

- ថ្វាយព្រះ ក្មួយ ! យីក្មួយឯងកើតអីក៏ស្គមស្លឹតស្លាំងម្ល៉េះ ?

- ខ្ញុំឥតឈឺថ្កាត់អីទេ អ៊ំ !

យាយចាន់ចាប់ម្លូមួយសន្លឹកមកបៀកផ្ទិតផ្ទង់ពមទៅក្នុងមាត់ ហើយទើបទំពារបណ្ដើរ បែរនិយាយទៅកាន់ស្ត្រីម្ចាស់ផ្ទះបណ្ដើរ :

- យីឯង យើងចុងខែអស្សុជហើយ ក៏នៅមានភ្លៀងមេធំៗ ម្ល៉េះ

- ខ្ញុំចូលចិត្តតែភ្លៀងធំៗ អីចឹង បើភ្លៀងរួច វាស្រស់ដីតែម្ដង ។ ឯភ្លៀងរលឹមធ្វើឲ្យធុញអផ្សុកណាស់ ។

- ចាំស អីចឹងមែន ។

ថាហើយយាយចាន់ គាត់ទាញកន្ថោរមកស្ដោះទឹកមាត់ពណ៌ឈាមឮសូរច្រចៗ រួចយកកន្សែងក្រហមមួយមកជូតមាត់ ទើបចាប់និយាយទៅទៀត :

- ខ្ញុំមកជួបនួនឯងនេះ ព្រោះចង់និយាយការបន្តិច ។

ឃាយនួនងាកមុខទៅចំកូនគាត់ ហើយថា :

- អារី ឯងបណ្ដាយកំផែដាំក្ដាតតែម្នាក់ឯងមិនកើតទេ ។ ត្រូវឯងទៅមើលផងទើបល្អ ។

នាងវិធារី ទទួលសំដីម្ដាយ ហើយក៏ដើរចេញពីទីនោះមិននិយាយថាអ្វីឡើយ ។ ចិត្តនាង នឹកបារម្ភ មិនដឹងជាយាយចាន់នេះ មកចាក់រុកម្ដាយខ្លួនដូចម្ដេចទេ !

ត្រង់នេះ ស្ត្រីចាស់ទាំងពីរឈប់ស្ងៀមមួយស្របក់ធំហាក់ដូចជាចង់សំឡឹងមើល ក្នុងចិត្តគ្នាទៅវិញទៅមក ។ យាយនួនគាត់ឆ្លៀតឱកាសនេះ ដើម្បីបៀកម្លូមួយម៉ាត់ លុះបានទំពាស្ដោះក្នុងកន្ថោរម្ដងហើយ ទើបគាត់សួរទៅយាយចាន់ :

- មានការអ្វីចាន់ ?

- អើរឿងកូនចៅឯងនោះ វាម្ដេចទៅហើយ ។ ឯងចាំប៊ុន- ធឿនចេញពីរៀន ទើបគិតគួរផ្សំផ្គុំវា ឬ យ៉ាងណា ?

- ហឺ ចាន់អើយ ខ្ញុំលាក់បាំងអី ។ ឥឡូវដូចចាន់ឯងដឹងស្រាប់ ឪពុក ប៊ុន- ធឿន ធ្លាក់ខ្លួនក្រហើយ ។ មានសង្ឃឹមតែលើបៀវត្សរ៍ប៊ុន- ធឿនតែម្យ៉ាងដូចគេសង្ឃឹមផ្កាយលើមេឃអីចឹង ។ ខ្ញុំមានកូនតែមួយ មានរំពឹងតែលើវា លុះជរាភាពមកដល់ខ្លួន ។ បើប្រសិនជាខ្ញុំឲ្យទៅថី ប៊ុន- ធឿនទៅ,ថីប៊ុន - ធឿន បន្តិចគេផ្លាស់ទៅធ្វើការនៅខេត្តនេះ បន្តិចទៅខេត្តនោះ ។ ឯប្រពន្ធតោងទៅតាមប្តី ។ ចំណែកខ្ញុំនឹងនៅម្នាក់ឯង ឥតនរណាជាពុំនឹក នេះម្យ៉ាង ។ ម្យ៉ាងទៀត ប៊ុន -ធឿន នេះធ្លាក់ក្រ ហើយ ម៉្លេះសមនឹងជញ្ជក់យកធនធានដែលខ្ញុំនឹងឲ្យទៅកូននោះ ទៅសងបំណុលមិនខាន ។ កូនខ្ញុំធ្វើម្ដេចនឹងបានសេចក្ដីសុខ ។

ដោយនិយាយវែងយ៉ាងនេះ ទឹកមាត់ក្រហមប្រតាកក៏ពុះពោរ ពេញមាត់ធ្វើឲ្យសំដីព្ធឡុលៗ ។ ដូច្នោះលុះយាយនួនគាត់ស្ដោះមួយប្រចរួច ទើបយាយចាន់គាត់ ឆ្លើយ :

- នួនឯងនិយាយយ៉ាងនេះចំជាត្រូវហើយ ។ បើប្រសិនជាខ្ញុំដូចនួនឯងវិញ ខ្ញុំក៏ផ្ដាច់ដែរ ។ គិតមើលសព្វៗទៅ យើងមិនទាន់ស៊ីស្លាបញ្ជាប់ពាក្យ ឬទទួលវត្ថុអ្វីជាខាន់ស្លាក៏នៅដែរ ។

លើកនេះ ត្រូវយាយចាន់គាត់ងាកទៅរកកន្ថោរវិញ ។ លុះគាត់បានសំរេចចិត្តហើយ ទើបអ្នកម្ចាស់ផ្ទះតបទៅវិញ :

ចាន់អើយ ខ្ញុំក៏គិតនឹងផ្ដាច់ដែរ តែមកតុះតុញមិនដឹងធ្វើដូចម្ដេច ។ នឹងធ្វើសំបុត្រទៅប្រាប់ចិក ប៊ុន-ថន ភ្លាមទៅ ដូចជាឯងចិត្តអាក្រក់ពេក ។ ឮតែគេខាតស្រូវភ្លាមក៏ថា ផ្ដាច់កូនផ្ដាច់ចៅភ្លាម ។

យាយចាន់គាត់បើកភ្នែកធំៗ ហាក់ដូចជាសំដីនេះ ធ្វើឲ្យគាត់ឆ្ងល់ពន់ពេក ។ ដូច្នេះគាត់ក៏ឆ្លើយ :



- ចាំបាច់ប្រាប់គេធ្វើអ្វី ។ យើងនៅតែស្ងៀមធ្វើហីទៅ ។ បើនរណាគេចូលមកដណ្ដឹង យើងគិតមើលល្មមលើក ក៏លើកឲ្យគេទៅ ។

ឱ ! នរណាអើយ គេនឹងហ៊ានចូលដណ្ដឹងឯងនោះ បើគេដឹងថា ឯងនៅជាប់ពាក្យសំដីចិក ប៊ុន-ថន ទៅហើយ ។

យាយចាន់គាត់សើចក្អាក ៗ ហើយថា :

នួនឯង និយាយយ៉ាងនេះចំពេញជាខុស ។ មានគេគិតចូលមកហើយ : តើឯងថាម៉េចទៅ ?

យាយនួនអរព្រើត កកិលចូលជិត ហើយសួរទៅភ្ញៀវគាត់ :

- អ្នកណាគេចង់ចូលមកនោះ ?

យាយចាន់ ខ្សឹបដាក់ត្រចៀក យាយនួន :

- ចិកណៃស៊ាន

ណៃស៊ាន ចៅកែកាណូតដើរទន្លេនោះហ៎ាស ?

- អើមានណៃស៊ានណាពីរបី ។ ឯងស្គាល់ចៅណៃស៊ិតកូនគេនោះទេ ។

-ខ្ញុំធ្លាប់ឃើញវាតែពីតូច ៗ ។

- ឥឡូវវាប៉ិនរកស៊ីណាស់ ដូចឪពុកវាអីចឹង ? ខ្ញុំឮដំណឹងថា បើចៅណៃស៊ិតនេះវាមានប្រពន្ធទៅ គេនឹងចែកឲ្យកាណូតពីរ ឡានកាំម៉្មុងមួយ និងដើមទុនមួយហ្មឺន ។ នេះនៅមិនទាន់គិតមាសពេជ្រអ្វីទៀតផង ។

យាយនួនគាត់ពព្រិចភ្នែកញ៉ូរ ហើយបែរសួរថា :

- ណៃ ស៊ិតនោះវាកើតឆ្នាំអីហ្ន៎ ?

យាយ ចាន់ដែលហាក់ដូចជាចាំតែពាក្យសួរនេះ និងអាលឆ្លើយនោះ ក៏ប្រាប់ទៅវិញភ្លាម :

- ឆ្នាំជូត ថ្ងៃអាទិត្យ ខែស្រាពណ៍ ។

យាយនួនគាត់ក៏ទទួលទន្ទេញហាក់ពុំចង់ឲ្យភ្លេច ឬមួយដោយហេតុដែលគាត់ធ្លាប់ទន្ទេញចម៌ ក្នុងពេលឪពោសថនោះក៏មិនដឹង ។

ឆ្នាំជូត .. ថ្ងៃអាទិត្យ ខែស្រាពណ៍ ...

ឆ្នាំជូត .. ថ្ងៃអាទិត្យ ខែស្រាពណ៍ ...

យាយចាន់គាត់សួរ ៖

- បើប្រសិនណាគេចូលមកមែន តើឯងព្រម ឬទេមើលទៅ ?

- អើ ចាំមើលស្រួលបួលសិន : ទុកដាក់កូនចៅនីមួយៗមិនងាយទេ ។

សំដីយាយនួនយ៉ាងនេះ ដូចជាគ្រាន់តែការពារឲ្យល្អមើលខាងក្រៅទេ

នៅល្ងាចនោះឯង កាលបើយាយចាន់លាគាត់ចុះផុតទៅ យាយនួន ក៏រួសរាន់រៀបខ្លួន ហើយកាន់ម្លូ បារី មួយស៊ងដាក់លើជើងពាន និងទៀន ១គូ ដើរតំរង់ទៅកុដិលោកគ្រូអានវត្តពោធិ៍ក្នុង ដែលមានព្រះនាមល្បីខាងហោរាសាស្ត្រ និងមន្តអាមគស្តោះព្រួស ។

ដល់ហើយ យាយនួនគាត់ចូលទៅថ្វាយបង្គំព្រះភិក្ខុអង្គនោះ ដែលមានសង្ឃដីកាសួរមក :

- យាយមានធុរៈអ្វី ?

- ខ្ញុំព្រះករុណាយកម្លូ ស្លា បារីនេះមក ប្រគេនលោកគ្រូម្ចាស់ហើយសុំ និមន្តលោកគ្រូម្ចាស់មើលដួងជតាកូន ខ្ញុំព្រះករុណាព្រោះ ខ្ញុំព្រះករុណាចង់ឲ្យវាមានគូស្រករ ។

លោកគ្រូអានក៏ទាញវត្ថពន្ធបោះលាតមក ព្រះហស្តស្តាំលោកចាប់ជាយម្ខាង ។ យាយនួនគាត់ក៏លើកពានបារី និងទៀនដាក់ លើជាយម្ខាង ។ ទើបលើកដៃប្រណម្យឡើងជាថ្មី ។ រួចហើយ លោកគ្រូអានក៏ទាញក្តារឈ្នួនមួយធំដែលទុកនៅប្របសំណឹងរើយកដីសមួយដុំ ហើយមកគង់នៅចំពោះមុខយាយនួន ទើបមានសង្ឃដីកាសួរថា :



- យាយ កូនយាយ កើតឆ្នាំអ្វី ?

- លោកម្ចាស់ វាឆ្នាំរោង ខែពិសាខ ថ្ងៃអង្គារ ។

លោកគ្រូអានកត់លើក្តារឈ្នួន រួចហើយទើបសួរទៀត :

តើខាងប្រុសនោះគេឆ្នាំអ្វី ?

ឆ្នាំជូត ថ្ងៃអាទិត្យ ខែស្រាពណ៍

លោកគ្រូអានក៏វាយលេខអត្ថៈមួយសន្ទុះ ទើបមានសង្ឃដីកា :

- យីយាយ លេខប្រសើរណាស់តើ ! តាំងតែពីអាត្មាចេះមើលហោមកពុំដែលឃើញលេខនរណាប្រកបគ្នាអីដល់ម្ល៉េះទេ ។

- បើដូច្នេះ ខ្ញុំព្រះករុណា សូមផ្សងចាក់គម្ពីរមើលម្តងទៀត ។

លោកគ្រូអានក៏ក្រោកឈរទាញគម្ពីរសាស្ត្រា ហើយស្រាយលាតក្របបញ្ចេញឲ្យឃើញស្លឹករឹតលាបទឹកមាសភ្លឺរន្ទាលដែលមាន ខ្សែចំណងពណ៌បៃតង ក្រហមលឿងចាក់ ឆ្លាស់គ្នាល្អចំឡែក ។ លោកលើកគម្ពីរនោះដាក់លើតោក ឈើ ១ លាបថ្នាំខ្មៅលំអដោយភ្ជីដាំខ្យង ហើយលោកលូកយកទៀនក្រមួនឃ្មុំ ១ ដែលយាយនួនបានយកមកប្រគេន មកអុជបិទនឹងក្របតោក ។ រួចស្រេច លោកក៏មានសង្ឃដីកា :

- អញ្ជើញយាយចាក់ទៅ ។

យាយនួនគាត់ក៏លើកហត្ថសំពះគ្រប់បីដង ហើយគាត់ស្ទួយតោកគម្ពីរនោះដាក់លើក្បាល ដៃឆ្វេងគាត់ទប់តោកដៃស្តាំគាត់យកកន្លាស់ធូបចាក់ជ្រៀត ទៅក្នុងស្លឹករឹតរួចហើយទើបគាត់ ប្រគេនតោកគម្ពីរនោះទៅព្រះថេរៈ ។ ភិក្ខុនេះ ក៏ទាញសាស្ត្រាយកមកលាតមើល ត្រង់កន្លែងដែលកន្លាស់ធូបសៀតចង្អុលរឿងត្រង់ព្រះមហោសថទៅ ជួបនឹងនាងអមរា ហើយមានព្រះហឫទ័យស្រឡាញ់នាងនេះពន់ប្រមាណ ។

លុះបានអានសព្វគ្រប់ហើយ លោកមានសង្ឃដីកាពន្យល់ :

- តាមអាត្មាយល់ថា ជាគាប់ប្រសើរក្រៃលែង ។

ឱព្រះភិក្ខុអើយ ! ទំនាយក្បួនតម្រា និងពាក្យអធិប្បាយតាមគម្ពីររបស់លោក ដែលជាអ្នកទ្រទ្រង់ព្រះពុទ្ធសាសនានៃព្រះបរមគ្រូនោះ បែរទៅជានាំជនពីរនាក់ដែលមានសេចក្តីស្នេហាទៅមកយ៉ាងធំបំផុត ឲ្យខានបានជួបគ្នាទៅវិញ ហាក់ដូចជា លោកជួយច្រាន គូសង្សារនេះ ទំលាក់ទៅរណ្តៅទុក្ខសង្រេង ។

យាយនួនកាលបើបានឮសង្ឃដីកា លោកគ្រូនេះអានដូច្នោះហើយ គាត់មានចិត្តសោមនស្សឥតឧបមា ។ គាត់យារជើងឈានមក ដូចជាស្រាលអស់ទាំងខ្លួនប្រាណគាត់ ព្រោះគាត់ដឹងថា ថៅកែណៃ ស៊ាននេះមានទ្រព្យធនស្តុកស្តម្ភណាស់ ។ ឯថៅណៃស៊ិតទៀត គាត់ក៏ធ្លាប់ឮអ្នកផង គេសរសើររាល់មាត់ថា ជាក្មេងកំលោះមានរូបរាងស្អាតបាតចេះចង់មាន ចង់បាន ហើយថែមទាំងចេះប្រណិប័តន៍ឪពុកម្តាយផង ។ ឱហៅគាប់ប្រសើរ ! សែនគាប់ប្រសើរ ! យាយនួនគាត់ខ្សឹបក្នុងចិត្តផ្ទៀបផ្ទឹមនាមយុវជន ទាំងពីរ : "ណៃស៊ិត វិធារី ! វិធារី ណៃស៊ិត " យីឈ្មោះទាំងពីរនេះសមគ្នាណាស់តើ ! ម្ល៉េះដល់បានគ្នាជាប្តីប្រពន្ធទៅ ហើយបើប្រសិនជាបណ្តើរគ្នាទៅណាមកណា សឹងមានអ្នកផងគេនឹងរបូតមាត់ថា យិះៗ! មិនខាន ... យាយមុខញញឹមប៉ប្រិម បិទមាត់ស្ទើរមិនជិត ដើរពង្រាយសេចក្តីសប្បាយទៅលើស្មៅ តាមផ្លូវចេញពីវត្តដូចជាអ្នកព្រោះស្រូវរោយគ្រាប់ ធញ្ញជាតិទៅក្នុងស្រែ ។

ប្រហែលជាមួយអាទិត្យក្រោយមក យាយនួនគាត់ទប់នឹងសេចក្តីរំខានដោយ ទន្ទឹងផ្លូវយាយចាន់ពុំបាន គាត់ក៏ឡើងជិះរ៉ឺម៉កឆ្ពោះទៅផ្ទះសំឡាញ់គាត់ :

- ចាន់អើយ លេខវាល្អណាស់ ខ្ញុំមិនថាអីទេ ឲ្យគេចូលមកចុះ ។





# ៦

បួន - ដប់ថ្ងៃ ក្រោយពីពេលដែលយាយនួន គាត់ទៅជួបនឹងយាយចាន់មកនោះ គេឃើញមានការរវល់ចំឡែកនៅផ្ទះមាតា នាងវិធារី ។

ស្ត្រីនេះតាំងក្រោកពីព្រឹកឡើង ក៏ដេញឲ្យយាយដៃបោសសំបុកពីងពាងដែលត្រដាងសន្ធឹងជាសំណាញ់ ឬជាអន្ទាក់សំរាប់ចាប់សត្វល្អិត តាមជញ្ជាំងនិងតាម គ្រឿងដំបូលព្រមទាំងបង្គាប់ឲ្យជូតលាងក្ដារកំរាលឲ្យរលោងយង់ ។ ឯនាងវិធារីនាងត្រូវវេនជុសខាត់គ្រឿងប្រាក់ស្លាបារី ជូតប៉ាន់តែ និងពែង ហើយមើលថែធ្នួនកុំឲ្យរបស់ទាំងនោះខ្វះវត្ថុអ្វីឡើយ គឺរកកំបោរច្រក បំពេញអក រកស្លាផ្កា ស្លាចំណិត ម្លូយ៉ាងស្រស់ៗមកបំរុងហិបហើយដាំ ទឹកក្ដៅបញ្ចាំលើជើងក្រាន ដើម្បីទុកឆុងតែឲ្យទាន់ត្រូវការ ។

យុវតីនេះគិតឆ្ងល់មមៃក្នុងចិត្តថា : ម៉ែអញគាត់ រៀបចំទទួលនរណាអេះ ។ ចំឡែកណាស់ !

យាយនួនគាត់រើសយកព្រំថ្មី ដែលតែងប្រើក្នុងឱកាសជា ឧឡារិកម្ដងៗមកក្រាលលើក្ដាររៀបប្រដាប់ទទួលភ្ញៀវតាមនិយមប្រពៃណី ។

មិនយូរប៉ុន្មាន គេក៏ឮសូររថយន្តមួយបើកមកឈប់នៅចំមុខផ្ទះ ។ យាយនួនក៏មានចិត្តរីករាយសែនសោមនស្ស ។

បន្តិចក្រោយមក គេឃើញស្ត្រីពីរនាក់មួយធាត់ស្អិចដូចត្បាល់ មួយស្គមក្រញ៉ីងដូចត្រីឆ្អើរ មួយស្លៀកខៀនបៃតង មួយស្លៀកខៀនស៊ីធូ ដៃលំអដោយកងពេជ្រ ដើងដោយស្បែកបាទដាំឱនភ្លឺរន្ទាល ។ ស្ត្រីទាំងពីរនេះច្រាន យាយចាន់ឲ្យដើរយោងមុខហើយក៏នាំគ្នា ត្រាច់ពីក្រោយ ម្នាក់មានដំណើរ អឹកអ៊ាកដូចទាកាប៉ា ម្នាក់រយ៉េវរយ៉ាវដូចកុកចាំមុខរង្វះ ។ លុះដល់ជិតហើយ យាយចាន់ក៏ស្រែកសួរថៅរ៉ៅទៅ :

- នួនអើយ ! ទៅណាហើយ ? នាងថូ និងនាងផិនគេមកលេង ។



យាយនួន ដែលឃ្លាំចាំតែភ្ញៀវនោះ ក៏ធ្វើជាភ្ញាក់ស្ទុះមកក្រៅ ហើយចរចាយ៉ាងរាក់ទាក់ :

- អញ្ជើញចាន់ : អញ្ជើញនាង ។ មកអញ្ជើញលើព្រំនេះមក ។

ថាហើយគាត់បែរទៅហៅម៉ែដៃឲ្យយកទឹកក្ដៅមកចាក់តែ ។ ចំណែក ស្ត្រីធាត់និងស្គម កាលបើបានដាក់ខ្លួនអង្គុយលើកម្រាលពិចិត្រនោះ ក៏លើកដៃសំពះ :

- ជំរាបសួរថៃ ។

· ថ្វាយព្រះនាង យាយនួនឆ្លើយដោយលើកដៃប្រណម្យសងវិញ ។

យាយចាន់ដែលអង្គុយនៅដើមអាសន៍គេនោះចាប់និយាយ :

- យីហ៊ុំ យប់មិញនេះ វារងាតិមធីតែម្ដងហើយ ។ ដណ្ដប់ភួយពីរបីជាន់ហើយ នៅតែមិនបាត់ ។

ស្ត្រីធាត់ដែលឈ្មោះថូនោះឆ្លើយឡើង :

- រងានៅផ្ទះគ្រាន់បើទេ ។ កាលពីល្ងាចថ្ងៃសៅរ៍មុននោះ ខ្ញុំបានជិះកាណូតទៅទារប្រាក់ ពីចិនម្នាក់នៅឯបាក់ព្រា ។ យប់នោះចំជារងាហើយ ស្ទើរកកឈាមក្នុងខ្លួនតែម្ដង ។

យាយនួនគាត់សួរ :

- ចុះណៃស៊ិតគេទៅណាទៅ បានជាគេបណ្ដោយឲ្យនាងពិបាកយ៉ាងនេះ?

- ចាំសថៃ គេរវល់ទៅមើលកូនគូលីច្រូតស្រូវឯជណ្ដើរស្វា ។

នាងថូដែលចង់ឆ្លៀតយកឱកាស ដើម្បីអួតពីកូនខ្លួន ក៏ប្រញាប់បន្ថែមសេចក្ដី :

- ឯកូនខ្ញុំ អាណៃស៊ិតនោះ វាទៅត្រួតគេបាញ់ថ្មឯភ្នំសំពៅ ដែលគេវាយបំបែកជីកយកទៅចាក់ធ្វើផ្លូវរទេះភ្លើងទៅមង្គលបុរី ។

ថាហើយ អ្នកនិយាយនេះ ក៏ទាញកន្ត្ោរមកស្ដោះទឹកមាត់ឮសូរព្រោកៗ

យាយនួនតបដោយតំអូញ :

ថូគេរវល់គ្រប់គ្នាតែម្ដង ប្រពន្ធដោយប្រពន្ធ ប្ដីដោយប្ដី កូនដោយកូន ។ ឯខ្ញុំហើយនៅតែផ្ទះ និងទៅសមាទានសីលប៉ុណ្ណោះ គ្មានបានរកអ្វីនឹងគេសោះ ។

- ចែគិតទៅបរលោកចំជាល្អហើយ ។ តាមអីខ្ញុំមានកូនច្រើន បើមិនខំទៅបានអីចែកឲ្យវា ។ ដូចចែនេះចំមហាសប្បាយហើយ ធ្វើតែទាន ហើយមានកូនតែមួយមិនមានព្រួយអីច្រើន ។ យីកូនចែធំប៉ុណ្ណាហើយ ? ខ្ញុំមិនដែលឃើញសោះ ។

យាយនួនគាត់ស្រែកហៅ :

- អារី អើយអារីទៅណាហើយ ? មីងឯងគេចង់ស្គាល់ឯង ?

នាងវិធារី កាលដែលនាងឃើញភ្ញៀវចំឡែកឡើងផ្ទះ នាងក៏ចូលលាក់ខ្លួននៅក្នុងបន្ទប់ ។ លុះនាងឮមាត់ម្ដាយស្រែកហៅដូច្នោះ នាងក៏ស្ទុះមកទាំងក្រៀមក្រំចេញមកក្រៅ ។ នាងខំទប់ កុំឲ្យសេចក្ដីហ្មងសៅចោលស្រមោលទៅ លើភក្ត្រនាងបាន ។ ក្នុងគ្រានោះ នាងវិធារីពាក់អាវទំនើបថ្មីពណ៌កុលាបខ្ចី លំអដោយជរសនៅសុរងកនិងស្លៀកសំពត់សូត្រព្រួយចេក ។ នាងចេញដើរមក មានទឹកមុខញញឹមស្ងួត ។

នាងថូ និងនាងផិនជាប្អូន កាលបើឃើញរូបឆោមលោមពណ៌នាង វិធារីស្រស់ប្រិមប្រិយដូច្នោះហើយ ក៏ចាប់ចិត្តស្រឡាញ់មហិមា ។នាងថូលាន់មាត់ថា :

យីក្មួយអញនេះល្អណាស់តើ ? ឯងអាយុប៉ុន្មានហើយ ?

នាងស្រីក្រមុំក៏លើកហត្ថសំពះហើយតប :

- ខ្ញុំអាយុ ១៧ឆ្នាំហើយ ។

អើក្មួយនេះនឹងធឹងណាស់តើ !

នាងវិធារី កើតសេចក្ដីអៀន ក៏ងប់មុខចុះពុំចេញស្ដី

យាយនួនគាត់ក៏និយាយឡើង :

- នាងអញ្ជើញនៅពិសាបាយនឹងខ្ញុំនេះហើយ ។



- ចាំសចែ កុំព្រួយ ខ្ញុំមានការបន្ទាន់បន្តិច ។

ស្ត្រីម្ចាស់ផ្ទះ ឈ្វេងយល់ចិត្តនាងភ្ញៀវ ដែលប្រាថ្នានិយាយការកំបាំង ពីមុខស្វាមីខ្លួននោះ ក៏ចរចាទៅកាន់បុត្រីគាត់ :

- អារីឯង ទៅមើលកំផៃតើវាធ្វើអី? បណ្ដោយវាម្នាក់ឯងមិនបានទេ ...

លុះនាងវិធារីចេញដើរផុតទៅ ទើបនាងថូបែរមុខសំឡឹងទៅយាយចាន់ ។ស្រីនោះ ក៏និយាយខ្សឹបៗ :

- នួន នាងថូនេះគេរកខ្ញុំជូនមកជាចាស់ជាទុំ ដើម្បីមកសុំចងស្ពានមេត្រី នឹងឯង ។ គេចង់ដណ្ដឹងកូនឯងឲ្យជាគូ នឹងកូនច្បងគេ ឈ្មោះណៃសិត តើឯងនឹងថាដូចម្ដេច ?

សំដីនេះ ធ្វើឲ្យទឹកជំនោរនៃសេចក្ដីត្រេកអរ ឡើងតឹងដល់បំពង់កយាយនួន ។ គាត់ខំប្រឹងស្មារតីទប់កុំឲ្យភ្លាត់មាត់ថា : យកចុះ ! យកចុះ ! ហើយទើបគាត់មានវាចាដោយសំរួល :

- នាងថូ នាងចង់បានជាសាច់សាលោហិតនឹងខ្ញុំនេះ ជាការគាប់ប្រសើរណាស់ តែកូនខ្ញុំវាខ្ចីគំនិតមិនសូវដឹងកិច្ចការរាក់ជ្រៅនៅឡើយទេ ។

នាងថូឆ្លើយ :

- មិនមែនទេចែ ។ ខ្ញុំស្គាល់មនុស្សណាស់ ។ កូនចែនេះ កិរិយាមារយាទគ្រអួបប្រពៃណាស់ ។

- បើនាងថាដូច្នោះ ហើយខ្ញុំក៏មិនថាអីដែរ តែត្រូវនាងរកគេមើលលេខជតាកូននាងនិងកូនខ្ញុំ តើសមនឹងគ្នាឬទេ ។ បើលេខឆ្លើយថាល្អទើបខ្ញុំដាច់ជាលើកជូននាងបាន ។

យាយនួន ដោយភ័យក្រែងនាងថូគេទៅរកហោរណាផ្សេងគន់គូរ ហើយនិងមានទំនាយពុំប្រកបនាំមកជាការជំទាស់ដល់សេចក្ដីគាប់ចិត្តរបស់គាត់នោះ គាត់ក៏រហ័សបន្ថយពាក្យឲ្យទៅរកលោកគ្រូអានជាប្រញាប់ :

- នាង រឿងខាងមើលប្ដីប្រពន្ធ ខ្ញុំថានៅដែនបាត់ដំបងនេះ គ្មានអ្នកណាផុត
  ជាងលោកគ្រូអានវត្តពោធិ៍ក្នុងទេ ។ បើលោកថាល្អហើយមិនដែលប្រែទៅ
  ជាអភ័ព្វបានទេ នៅសុខនឹងគ្នាដល់ស្លាប់រៀងខ្លួន ។
- ចាំះចែ ចាំខ្ញុំទៅរកលោកគ្រូអានមើល ។ តើនាងនោះឆ្នាំអី ?
- នាងសួរចាន់ចុះ ចាន់គេដឹងស្រាប់ហើយ ។

យាយចាន់ឆ្លើយ :

- ខ្ញុំចាំហើយនាងថូ ។ ម្ដេចយើងល្មមលាគេទៅហើយឬដឹង ?
- ចាំះ ។

ថាហើយ ស្ត្រីជាត់ និងស្ដមក៏លើកដៃសំពះលាយាយនួនប្រុងនឹងចុះទៅ ។ នាងធិនដែលអំបាញ់មិញ មិនបាននិយាយថាអ្វីសោះ ក៏និយាយទៅកាន់នាងថូ :

- កូននេះត្រូវហើយ , សមនិងអាស៊ិត មុខជាវាពេញចិត្តវាហើយ ។ បើបាន
  គ្នាជាប្ដីប្រពន្ធទៅអាស៊ិតលែងដើរលេងយប់ពាសវាលពាសកាលទៀតហើយ
  មើលទៅ ។

នាងថូ ដែលនឹងភ័យក្រែងយាយនួនគាត់ឮសំដីនេះ នាំឲ្យខូចការផ្សេងៗ នោះ ក៏និយាយបន្ទោសទាំង ក្ដាញ់ :

- ៈមេគន្ធិន កុំនិយាយយ៉ាំងនេះហង !

តែខណៈនោះយាយនួន ដែលមានព្រលឹងអណ្ដែតទៅលើអាកាស មិនបានជាចាប់ចិត្តស្ដាប់សំដីលើកក្រោយនេះទេ ។ បើប្រសិនជាគាត់កុំរវល់តែអរហួសពេក ប្រហែលជាត្រចៀកគាត់នៅចំហរខ្លះ ហើយប្រហែលជាគាត់មានសង្ស័យកើតនិងស៊ើបសួរដល់កិរិយាមាយាទ ចៅណែសិតផងពុំខាន ហើយប្រហែលជាគ្មានរឿងនេះនិទានទៅទៀតឡើយ ។

លុះឮសួរឡានបើកទៅផុតហើយ នាងវិធាវីក៏ចេញមកសួរម្ដាយ :



- ម៉ែអ្នកណាហ្នឹងហ្ន៎ ? មើលតែស្រីអ្នកមានស្រុកព្រៃតែម្ដងហើយ ។ ចំណាស់
  ប៉ុណ្ណឹងហើយនៅតែស្លៀកខៀនពណ៌ ពាក់មាសរាប់គីឡូ ។ មនុស្សមានសម្បត្តិ
  យ៉ាំងនេះ ខ្ញុំមិនចង់ជួបមុខទេ ។

យាយនួនដែលស្មារតីនៅតែរវល់តែត្រេកអរនោះ ក៏មិនបានឮពាក្យកូនចរចាទេ ។ គាត់ស្ដាប់ចាប់បានតែចុងកន្ទុយសំដី គាត់សំឡឹងមុខកូនគាត់ ហើយគាត់ធ្វើ "ហ៊ឺសៗ ! " ប៉ុណ្ណោះ ក៏ដើរចេញទៅ ។

